**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# ផែនការយុទ្ធសាស្ត្រថវិកា
# ឆ្នាំ ២០២០-២០២២




**ថ្ងៃព្រហស្បតិ៍ ៦កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣**

**ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៩**

# មាតិកា

I. សេចក្តីផ្តើម ..... ៣
១.១. ចក្ខុវិស័យ ..... ៣
១.២.តួនាទី និងបេសកកម្ម ..... ៤
១.៣.គោលបំណង និងគោលដៅ ..... ៤
១.៤.លទ្ធផលសម្រេចបានក្នុងឆ្នាំ២០១៨ ធៀបនឹងសូចនាករក្នុងឆ្នាំ ..... ៥
កម្មវិធីទី១៖ បន្តថែទាំ និងកែលម្អហេដ្ឋារចនាសម្ព័ន្ធជនបទ ..... ៥
កម្មវិធីទី២៖ លើកកម្ពស់គុណភាពនៃការផ្តល់សេវាសាធារណៈជនបទ ..... ៥
កម្មវិធីទី៣៖ ការអភិវឌ្ឍធនធានមនុស្ស និងពង្រឹងស្ថាប័ន ..... ៧
II. លទ្ធផលសម្រេចបានក្នុងនីតិកាលទី៥ និងបញ្ហាប្រឈមសម្រាប់ឆ្នាំ២០១៩ ..... ៩
២.១.វិធានការគោលនយោបាយអាទិភាពក្នុងវិស័យអភិវឌ្ឍន៍ជនបទ ឆ្នាំ២០២០-២០២២ ..... ១១
២.២.យុទ្ធសាស្ត្រ ..... ១២
២.៣. គោលបំណងគោលនយោបាយ ..... ១២
III. ការរៀបចំកម្មវិធី ..... ១៣
១-កម្មវិធីទី១ ៖ អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងគមនាគមន៍ ..... ១៣
២.កម្មវិធីទី២ ៖ កែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ ..... ១៥
៤.កម្មវិធីទី៤ ៖ សេវាគាំទ្ររដ្ឋបាល ហិរញ្ញវត្ថុ និងកិច្ចការទូទៅ ..... ២០
IV. រចនាសម្ព័ន្ធថវិកាកម្មវិធីក្រសួងអភិវឌ្ឍន៍ជនបទ ..... ២២
តារាងឧបសម្ព័ន្ធផែនការយុទ្ធសាស្ត្រថវិកា ..... ២៤
V.ការកំណត់ធនធាន ..... ៤២
VI- សេចក្តីសន្និដ្ឋាន ..... ៥៨

# ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២០-២០២២
# របស់ក្រសួងអភិវឌ្ឍន៍ជនបទ

## I. សេចក្តីផ្តើម

### ១.១. ចក្ខុវិស័យ

ផែនការយុទ្ធសាស្ត្រនេះមានចក្ខុវិស័យ ចូលរួមកាត់បន្ថយភាពក្រីក្ររបស់ប្រជាជននៅតំបន់ជនបទ និងជំរុញកំណើនសេដ្ឋកិច្ចជនបទឲ្យបានឆាប់រហ័ស ដើម្បីលើកកម្ពស់គុណភាព និងគុណតម្លៃនៃជីវិតរបស់ប្រជាជនជនបទឲ្យបានប្រសើរឡើង ។

### ១.២.តួនាទី និងបេសកកម្ម

ផែនការយុទ្ធសាស្ត្រនេះ មានបេសកកម្ម លើកកម្ពស់គុណភាព និងគុណតម្លៃនៃជីវិតរបស់ប្រជាជននៅជនបទ តាមរយៈការធ្វើឲ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត គមនាគមន៍ និងសេវាសាធារណៈនៅតាមតំបន់ជនបទ អប់រំសុខភាព ធ្វើឲ្យប្រជាជនជនបទទទួលបានផាសុខភាព និងមានជីវភាពល្អប្រសើរ តាមរយៈការបង្កើតការងារ និងមុខរបរដើម្បីលើកកម្ពស់លក្ខខណ្ឌជីវិតរស់នៅឲ្យបានល្អប្រសើរ ។

### ១.៣.គោលបំណង និងគោលដៅ

ផែនការយុទ្ធសាស្ត្រនេះ បានតម្រង់គោលដៅស្របគ្នានឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ របស់រាជរដ្ឋាភិបាល និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជាឆ្នាំ ២០៣០ ។

- **គោលបំណង**

ផែនការយុទ្ធសាស្ត្រនេះ មានគោលបំណងប្រែក្លាយតំបន់ជនបទនៃព្រះរាជាណាចក្រកម្ពុជា ជាតំបន់អភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ដោយមានហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់ប្រទាក់ក្រឡាគ្នានៅតាមជនបទ ។ ធ្វើឲ្យប្រជាជនជនបទ ទទួលបានការអប់រំសុខភាពអនាម័យ រស់នៅក្នុងបរិស្ថានស្អាត មានការងារ និងមុខរបរសមរម្យ ។

- **គោលដៅ**

គោលដៅចម្បងនៃផែនការយុទ្ធសាស្ត្រនេះ ដើម្បីលើកកម្ពស់គុណភាព និងគុណតម្លៃនៃជីវិតរស់នៅរបស់ប្រជាជនជនបទប្រកបដោយបរិយាប័ន្ន ទាំងផ្នែកសេដ្ឋកិច្ច សង្គម និងវប្បធម៌។ ទិសដៅសំខាន់ៗនៃផែនការយុទ្ធសាស្ត្រមានដូចតទៅ៖

- ជំរុញ និងលើកទឹកចិត្តមន្ត្រីរាជការក្រសួងអភិវឌ្ឍន៍ជនបទឲ្យទទួលបានការបណ្តុះបណ្តាលជំនាញយ៉ាងតិច ៨០ម៉ោងក្នុងមួយឆ្នាំសម្រាប់មន្ត្រីម្នាក់ៗ
- ស្តាបនាឲ្យបានផ្លូវជនបទប្រវែង១,០០០ គ.ម និងផ្លូវចាក់កៅស៊ូប្រវែង ៥៥០ គម
- ថែទាំ ជួសជុល កែលម្អផ្លូវជនបទប្រវែងឲ្យបានប្រវែង ១២,០០០ គ.ម
- សម្រេចឲ្យបាននូវគោលដៅរួម៩០%នៃការផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យជនបទនៅឆ្នាំ២០២៣
- ជំរុញខេត្តយ៉ាងតិចចំនួន ០៥ ឈានទៅឈប់បន្ទោរបង់ពាសវាលពាសកាល (ODF)
- បង្កើតមុខរបរ និងការងារឲ្យបាន ១,៥០០នាក់ ជូនប្រជាជនជនបទដើម្បីលើកកម្ពស់លក្ខខណ្ឌជីវិតរស់នៅបានល្អប្រសើរ
- បង្កើនការផ្ទេរមុខងាររឹមជ្ឈការ និងវិសហមជ្ឈការ ៥០ស្រុក បន្ថែមទៀត
- បង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញមូលដ្ឋានចល័តចំនួន ១០កន្លែង
- សាងសង់ទីទួលសុវត្ថិភាពការពារគ្រោះធម្មជាតិបន្ថែមចំនួន ២០កន្លែង
- ធ្វើបច្ចុប្បន្នភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ៥០០ភូមិ
- កំណត់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិចឲ្យបាន ២០០សហគមន៍
- បន្តចូលរួមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៣ និងទី៤ ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ១.៤.លទ្ធផលសម្រេចបានក្នុងឆ្នាំ២០១៨ ធៀបនឹងសូចនាករក្នុងឆ្នាំ

### ➢ កម្មវិធីទី១៖ បន្តថែទាំ និងកែលម្អហេដ្ឋារចនាសម្ព័ន្ធជនបទ

គម្រោងវិនិយោគផ្ទាល់ ឆ្នាំ២០១៨ មានចំនួនសរុប ១០៥ គម្រោង ប្រវែងសរុប ៤៧៦ គ.ម ស្ពានបេតុងចំនួន ២៦ កន្លែង ប្រវែងសរុប ១ ៣១១ម និងសំណង់សិល្បការ្យ ចំនួន ៥៤៣កន្លែង ក្នុងនោះមាន ផ្លូវកៅស៊ូប្រវែង ៨២,៣៥ គ.ម ។ ផ្លូវបេតុងប្រវែង ៦,៧៤គ.ម ។ ផ្លូវក្រាលក្រួសក្រហមប្រវែង ៣៨៦,៩១ គ.ម ។ ស្ពានបេតុង ២៦កន្លែងប្រវែង ១ ៣១១ម ។ សំណង់សិល្បការ្យចំនួន ៥៤ កន្លែង ត្រូវបានអនុវត្ត។ គម្រោងថែទាំផ្លូវលក្ខណៈខួប ឆ្នាំ២០១៨ មានផ្លូវក្រាលក្រួសក្រហមចំនួន ៨០ខ្សែ ប្រវែងសរុប ៤៩០,៤៩ គ.ម និងសំណង់សិល្បការ្យ ចំនួន ១៤២កន្លែង ។ គម្រោងថែទាំផ្លូវលក្ខណៈប្រចាំមានចំនួន ១៩២ ខ្សែ ប្រវែងសរុប ១ ៥៦៧,៥៩គ.ម ក្នុងនោះមាន ផ្លូវក្រាលក្រួសក្រហមប្រវែង ១ ០១៣,៦១គ.ម ។ ផ្លូវកៅស៊ូប្រវែង ៥៥៣,៩៨គ.ម ផ្លូវបេតុងប្រវែង ១៥,៨០គ.ម ។ គម្រោងជួសជុលបន្ទាន់អនុវត្តបានប្រវែង ២៦៧,៩៥ គ.ម និងលូមូល ចំនួន ២៦កន្លែង លូប្រអប់ចំនួន ០១កន្លែង និងស្ពានចំនួន ០១កន្លែង ត្រូវបានសម្រេចតាមផែនការ ១០០% ។ បានចុះស្រង់ទិន្នន័យខ្សែផ្លូវជនបទប្រចាំឆ្នាំ ចំនួន ៣០២ ខ្សែ ស្មើនឹង ៧០២,៩២គ.ម ។ បានធ្វើបច្ចុប្បន្នភាពខ្សែផ្លូវជនបទប្រចាំឆ្នាំ ចំនួន ៣១៦ខ្សែ ស្មើនឹង ២ ៤០០,៣៥គ.ម ។

## ➢ កម្មវិធីទី២៖ លើកកម្ពស់គុណភាពនៃការផ្តល់សេវាសាធារណៈជនបទ

កម្មវិធីទី២ មានអនុកម្មវិធីចំនួន ៥ មានគោលដៅជម្រុញលើកកម្ពស់គុណភាពសេវាសាធារណៈនៅតាមតំបន់ជនបទឲ្យបានល្អប្រសើរ ក្នុងនោះមានសេវាផ្គត់ផ្គង់ទឹកស្អាត សេវាអប់រំសុខភាពអនាម័យជនបទ អភិវឌ្ឍន៍ចម្រុះសម្រាប់សហគមន៍ជនបទ ការងារអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ និងអភិវឌ្ឍន៍ អភិរក្សការងារគ្រប់គ្រង និងអភិវឌ្ឍន៍ជនជាតិដើមភាគតិច ។ លទ្ធផលសម្រេចបានក្នុងឆ្នាំ២០១៨មាន អណ្តូងស្នប់ចំនួន ១ ០២៧អណ្តូង ត្រូវបានសាងសង់ ។ អណ្តូងស្នប់ ចំនួន ៣៤០អណ្តូង ត្រូវបានជួសជុលឲ្យដំណើរការឡើងវិញ ។ ស្រះចំនួន ១៨ កន្លែងត្រូវបានសាងសង់ជូនសហគមន៍ និងស្រះទឹកចំនួន០៨កន្លែងផ្សេងទៀតត្រូវបានស្តារឡើងវិញ ។ អាងត្រងទឹកភ្លៀងចំនួន ៣៣អាង ត្រូវបានសាងសង់ថ្មីបន្ថែមទៀត ។ ស្តារប្រឡាយចំនួន ០២ខ្សែ ប្រវែង ៣ ០០០ម៉ែត្រជូនកសិករនៅខេត្តត្បូងឃ្មុំ ។ ធុងចម្រោះចំនួន ២ ៣៧០ ធុង ត្រូវបានចែកតាមគ្រួសារក្រីក្រ និងប្រព័ន្ធចែកចាយទឹកតាមទុយោចំនួន ០២ ប្រព័ន្ធត្រូវបានសាងសង់រួចរាល់សម្រាប់ប្រើតាមភូមិ ។

បង្គន់អនាម័យចាក់ទឹកតាមផ្ទះឯកជនចំនួន ៩២៨ បង្គន់ ត្រូវបានសាងសង់ និងផ្តល់ជូនប្រជាជនរួចរាល់ និងបង្គន់អនាម័យចាក់ទឹកតាមទីសាធារណៈចំនួន ០៨បង្គន់ ក៏ត្រូវបានសាងសង់រួចហើយផងដែរ ។ ចានបង្គន់ចំនួន ១ ៥៩២ ត្រូវបានបដិភាគជូនផ្ទះឯកជនដើម្បីសាងសង់ដោយខ្លួនឯង និងចានបង្គន់ចំនួន ០៣ ត្រូវបានផ្តល់ជូនសម្រាប់សាងសង់បង្គន់សាធារណៈ ។ ប្រជាជនចំនួន ១៤៨ នាក់ ត្រូវបានអប់រំសុខភាពអនាម័យ ការរស់នៅស្អាត ។ បានពន្យល់ណែនាំប្រជាពលរដ្ឋអំពីសារៈសំខាន់នៃការសាងសង់បង្គន់អនាម័យក្នុងខេត្តគោលដៅចំនួន ១៣ រួមមានខេត្តកំពត កំពង់ចាម កំពង់ស្ពឺ ស្ទឹងត្រែង កំពង់ឆ្នាំង កោះកុង សៀមរាប បាត់ដំបង ស្វាយរៀង ឧត្តរមានជ័យ ក្រចេះ ប៉ៃលិន និងខេត្តព្រះសីហនុ ។ បានបំផុសការសាងសង់បង្គន់អនាម័យដល់សហគមន៍តាមភូមិគោលដៅនៅក្នុងខេត្តក្រចេះ កំពង់ស្ពឺ កំពង់ចាម កំពង់ឆ្នាំង កំពត ស្វាយរៀង កោះកុង បៃលិន បាត់ដំបង ស្ទឹងត្រែង និងខេត្តឧត្តរមានជ័យ ។ បានរៀបចំយុទ្ធនាការផ្សព្វផ្សាយអនាម័យនៅក្នុងខេត្តគោលដៅទាំង១៤ រួមមានខេត្តព្រះសីហនុ កំពត កោះកុង សៀមរាប ក្រចេះ កំពង់ស្ពឺ កំពង់ឆ្នាំង ប៉ៃលិន បាត់ដំបង ស្ទឹងត្រែង ឧត្តរមានជ័យ ស្វាយរៀង ត្បូងឃ្មុំ និងខេត្តកំពង់ចាម ។ បានចុះអនុវត្តការលើកកម្ពស់អនាម័យនៅតំបន់សំណង់មិនរៀបរយ ចំនួន ០៦ លើក មានអ្នកចូលរួមសរុប ចំនួន ៦៦១ នាក់ ។

បណ្តុះបណ្តាលពង្រឹងសមត្ថភាព គ.អ.ភ ស្តីពីតួនាទីភារកិច្ច និងការធ្វើផែនការសកម្មភាពអភិវឌ្ឍន៍ភូមិចំនួន ១១១វគ្គ ក្នុងភូមិគោលដៅចំនួន ៧៧៧ភូមិ មានសិក្ខាកាមចូលរួមសរុប ៣ ៨៨៥នាក់ ។ ធ្វើបច្ចុប្បន្នភាព គ.អ.ភ បានចំនួន ៥ ៤៣៧ភូមិ ក្នុងនោះ ភូមិមានសកម្មភាពចំនួន ៣ ៣២២ភូមិ ភូមិគ្មាន

សកម្មភាពចំនួន ១ ៦៦៨ភូមិ ភូមិមានអង្គការគាំទ្រចំនួន ២១ភូមិ ផ្លាស់ប្តូរសមាជិកភាពថ្មីចំនួន ៤ ៧៨២នាក់ នៃភូមិបច្ចុប្បន្នភាព ។ បានផ្តល់កូនឈើហូបផ្លែចម្រុះចំនួន ២ ៨០០ដើម កូនឈើចម្រុះចំនួន ៤០០ដើម ពូជមាន់ចំនួន ៥០០ក្បាល ពូជត្រីចំនួន ១៥ ០០០ក្បាល និងស្រះចិញ្ចឹមត្រីជាលក្ខណៈគ្រួសារចំនួន ៥០ស្រះ នៅភូមិចំនួន ០៥ភូមិ ក្នុងខេត្តចំនួន ០៤ គឺ ខេត្តកំពង់ស្ពឺ កំពង់ឆ្នាំង ព្រៃវែង និងស្វាយរៀង ។ បណ្តុះបណ្តាលដល់គ្រួសារសហគមន៍ស្តីពី សួនដំណាំគ្រួសារ និងរបៀបធ្វើជីកំប៉ុស្តិ៍ចំនួន ១៦សហគមន៍ចូលរួមសរុបចំនួន ៤៨០នាក់ ស្រីចំនួន ២៥៣នាក់ ។ ផ្តល់ពូជបន្លែចម្រុះដល់គ្រួសារសហគមន៍ចំនួន ៦៦០គ្រួសារ ។ បានបណ្តុះបណ្តាល ស្តីពីការត្រៀមបង្ការ និងកាត់បន្ថយគ្រោះមហន្តរាយក្នុងសហគមន៍ចំនួន ១៣វគ្គ នៅខេត្តកំពង់ស្ពឺ សៀមរាប បន្ទាយមានជ័យ និងខេត្តកំពត មានអ្នកចូលរួមសរុបចំនួន ៤៥៥នាក់ ក្នុងនោះមានស្រីចំនួន ១៦០នាក់ ។ មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តកំពង់ស្ពឺ បានបើកវគ្គបណ្តុះបណ្តាល ចំនួន ០៨មុខជំនាញមាន ២៦វគ្គ សិក្ខាកាម ៧៣៣នាក់ ស្រី ៣៣៥នាក់ ។ មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តតាកែវបានបើកវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទាំងនៅក្នុងមជ្ឈមណ្ឌល និងក្រៅមជ្ឈមណ្ឌល បានចំនួន ៣៤ វគ្គ សិក្ខាកាមសរុបចំនួន ៦៨០នាក់ ស្រី ចំនួន ៣១៣នាក់ ។

បានចុះពិនិត្យ និងតាមដានការអនុវត្តគម្រោងសិប្បកម្មផលិតសាប៊ូ នៅខេត្តកំពង់ធំ ។ បានរៀបចំសិក្ខាសាលាស្តីពី នវានុវត្តន៍ហិរញ្ញវត្ថុសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចជនបទ នៅខេត្តស្វាយរៀង ។ បានបណ្តុះបណ្តាលការធ្វើសិប្បកម្មផលិតសាប៊ូ នៅខេត្តកំពង់ធំ និងខេត្តកំពង់ឆ្នាំង ។ បានរៀបចំសិក្ខាសាលាស្តីពីការរៀបចំគម្រោងការអភិវឌ្ឍសេដ្ឋកិច្ចជនបទនៅខេត្តមណ្ឌលគិរី ។ បានរៀបចំសិក្ខាសាលាស្តីពីការផ្លាស់ប្តូរបទពិសោធន៍ជោគជ័យ និងបញ្ហាប្រឈមរបស់សហគមន៍សន្សំប្រាក់ នៅខេត្តកំពង់ឆ្នាំង ។ បានរៀបចំពិធីតាំងពិព័រណ៍ពាណិជ្ជកម្មផលិតផលខ្មែរ នៅខេត្តត្បូងឃ្មុំ និងខេត្តកំពង់ឆ្នាំង ។ បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយពីគំនិតផ្តួចផ្តើម និងការគ្រប់គ្រងអាជីវកម្មខ្នាតតូច នៅខេត្តពោធិ៍សាត់ ។

បានចូលរួមកិច្ចប្រជុំពេញអង្គ ស្តីពីការពិនិត្យ ពិភាក្សា និងអនុម័តលើសេចក្តីព្រាងបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍ជនជាតិដើមភាគតិច ព្នង ព្រៅ និងគ្រឹង ចំនួន ០៨សហគមន៍ នៅខេត្តស្ទឹងត្រែង និងខេត្តរតនគិរី ។ បានចូលរួមកិច្ចប្រជុំ សិក្សាភូមិគោលដៅដែលត្រូវបង្កើតសហគមន៍ជនជាតិដើមភាគតិចព័រ និងកួយ ចំនួន ០៥សហគមន៍ នៅខេត្តពោធិ៍សាត់ និងខេត្តកំពង់ធំ ។ បានចូលរួមចុះសិក្សា និងវាយតម្លៃបឋមលើគម្រោងបង្កើតសារមន្ទីរជាតិ ជនជាតិដើមភាគតិច លើដីទំនេរទំហំ ០៥ហិចតា ស្ថិតនៅខេត្តមណ្ឌលគិរី ។ បានរៀបចំទិវាអន្តរជាតិជនជាតិដើមភាគតិចពិភពលោកលើកទី ២៤ នៅខេត្តព្រះវិហារ ពិនិត្យ និងវិភាគរាល់ឯកសារស្រាវជ្រាវ កែសម្រួលអក្ខរាវិរុទ្ធ វាក្យស័ព្ទ និងឃ្លា និងបញ្ចូលឯកសារទៅក្នុងប្រព័ន្ធទិន្នន័យ ។

- **កម្មវិធីទី៣៖ ការអភិវឌ្ឍធនធានមនុស្ស និងពង្រឹងស្ថាប័ន**

ឆ្នាំ ២០១៨ មន្ត្រីរាជការក្រុបខណ្ឌសរុបមានចំនួន ១ ៨២៩ នាក់ ប្រៀបធៀបនឹងចំនួនមន្ត្រីរាជការ

កាលពីឆ្នាំ ២០១៧ គឺមានការកើនឡើងចំនួន ៦៨នាក់។ ក្រសួងបានទទួលលិខិតចូលចំនួន ១ ០៥៦ ច្បាប់ លិខិតចេញក្រៅក្រសួងចំនួន ១ ៤២៦ច្បាប់ ចុះលេខប្រកាស និងសេចក្តីសម្រេចនានាចំនួន ១៣៧ច្បាប់ និងចុះលេខលិខិតបេសកកម្មចំនួន ៥ ០៨៩ច្បាប់ ។ ទទួលបានសំណើ សំណូមពររបស់ប្រជាពលរដ្ឋនៅមូលដ្ឋានតាមរយៈវេទិកាសាធារណៈថ្នាក់ជាតិសរុប ចំនួន ១៨៨ករណី ដោះស្រាយជូនប្រជាពលរដ្ឋបានចំនួន ៣៤ករណី ។ ក្រសួងបានអនុវត្តចំណាយចរន្តសរុបចំនួន ១១៨ ៨០៦ ៧២៤ ៣១៨ រៀល ស្មើនឹង ៩៨,៩២% និងចំណាយមូលធនអនុវត្តបានចំនួន ១៦៩ ៧៩៣ ៣២២ ៤៨០ រៀល ស្មើនឹង ៩៩,៨៨% នៃច្បាប់ថវិកា ។ បានរៀបចំផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជនបទឆ្នាំ ២០១៩-២០២៣ សម្រាប់អនុវត្តយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤ ។ រៀបចំផែនការសកម្មភាពដំណាក់កាលទី៣ (MAP3)ក្នុងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០១៩ ។ រៀបចំផែនការវិនិយោគសាធារណៈ PIP ២០១៩-២០២១ ។ រៀបចំផែនការយុទ្ធសាស្រ្តថវិកាឆ្នាំ ២០១៩-២០២១ និងរៀបចំផែនការថវិកាឆ្នាំ ២០១៩ របស់ក្រសួងអភិវឌ្ឍន៍ជនបទ ។ ចុះពិនិត្យការអនុវត្តផែនការតាមកម្មវិធីឆ្នាំ ២០១៨ និងណែនាំការរៀបចំផែនការថវិកាឆ្នាំ ២០១៩-២០២១ បានចំនួន ១០ ខេត្ត ។ ចុះតាមដានត្រួតពិនិត្យការអនុវត្តផែនការថវិកាតាមកម្មវិធីឆ្នាំ ២០១៨ និងណែនាំពីការធ្វើស្ថិតិរបស់មន្ទីរអភិវឌ្ឍន៍ជនបទរាជធានី-ខេត្ត ចំនួន ២៥ រាជធានី ខេត្ត ។ ចុះធ្វើការអង្កេតស្រាវជ្រាវករណីបណ្តឹងរឿងអាស្រូវពុករលួយរបស់ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តបាត់ដំបង ។ ចុះធ្វើអធិការកិច្ចលើកាងារគ្រប់គ្រងចំណូល-ចំណាយ និងការប្រើប្រាស់ថវិការដ្ឋការិយបរិច្ឆេទ២០១៧ នៅមន្ទីរអភិវឌ្ឍន៍ជនបទរាជធានី-ខេត្ត ចំនួន ២៣ខេត្ត ។ ចុះធ្វើសវនកម្មលើការគ្រប់គ្រងរដ្ឋបាល ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ថវិកាតាមកម្មវិធី ឆ្នាំ ២០១៧ -២០១៨ និងចុះពិនិត្យជាក់ស្តែងការងារសាងសង់ ជួសជុលអណ្តូងទឹក និងសាងសង់បង្គន់អនាម័យដោយប្រើប្រាស់ថវិការដ្ឋ នៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្តចំនួន ២៥ ។

មន្ត្រីចូលរួមសិក្ខាសាលាក្នុង និងក្រៅប្រទេសសរុប ចំនួន ៣ ០៨៦នាក់ ក្នុងនោះស្រីចំនួន ៦៥៤ នាក់ ចូលរួមវគ្គបណ្តុះបណ្តាលក្នុង និងក្រៅប្រទេស ចំនួន ១ ២២៤នាក់ ក្នុងនោះស្រីចំនួន ៣២៩នាក់ ចូលរួមទស្សនកិច្ចសិក្សាក្នុង និងក្រៅប្រទេស ចំនួន ៣៩នាក់ ក្នុងនោះស្រីចំនួន ០៣នាក់ ។ បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយគោលនយោបាយអភិវឌ្ឍន៍ធនធានមនុស្ស និងពិភាក្សាសេចក្តីព្រាងផែនការយុទ្ធសាស្រ្តការអភិវឌ្ឍធនធានមនុស្ស ។ រៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពីការវាយតម្លៃតម្រូវការវគ្គបណ្តុះបណ្តាលជាមួយមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ។ រៀបចំវគ្គបណ្តុះបណ្តាលស្តីពីការរៀបចំគម្រោងមេរៀនសម្រាប់មជ្ឈមណ្ឌល និងមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ។ បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីជំនាញក្នុងការសម្របសម្រួលសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលសម្រាប់មន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ។

រៀបចំវគ្គបណ្តុះបណ្តាលស្តីពីសញ្ញាណទូទៅផ្នែកប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុ(FMIS)សម្រាប់មន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ។

- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តព្រៃវែង បានបណ្តុះបណ្តាលរយៈពេលវែង និងរយៈពេលខ្លី បានចំនួន ៤៥ វគ្គ ដែលមានសិក្ខាកាមចូលរៀនសរុបចំនួន ៧៤៤ នាក់ (ស្រី ៤០៨ នាក់)
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តស្វាយរៀង បានបណ្តុះបណ្តាលរយៈពេលវែង និងរយៈពេលខ្លី បានចំនួន ២៨ វគ្គ ដែលមានសិក្ខាកាមចូលរៀនសរុបចំនួន ៥៩៨ នាក់ (ស្រី ២៥៧ នាក់)
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម បានបណ្តុះបណ្តាលរយៈពេលវែង និងរយៈពេលខ្លី ចំនួន ១៥ វគ្គ មានសិក្ខាកាមចូលរៀនសរុបចំនួន ៣៧៥ នាក់ (ស្រី ១៤៦ នាក់)
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តបាត់ដំបង បានដំណើរការវគ្គបណ្តុះបណ្តាលរយៈពេលវែង និងរយៈពេលខ្លី ចំនួន ១៦ វគ្គ សិក្ខាកាមចូលរៀនសរុបចំនួន ២៨៩ នាក់ (ស្រី ១២៥ នាក់)
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តពោធិ៍សាត់ បានបណ្តុះបណ្តាលរយៈពេលវែង និងរយៈពេលខ្លី ចំនួន ២០ វគ្គ មានសិក្ខាកាមចូលរៀនសរុបចំនួន ៤៦៥ នាក់ (ស្រី ២៨៦ នាក់)
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តកំពតបានបណ្តុះបណ្តាលរយៈពេលវែង និងរយៈពេលខ្លី ចំនួន ០៩ វគ្គ មានសិក្ខាកាមចូលរៀនសរុបចំនួន ១៦១ នាក់ (ស្រី ៣៤ នាក់) ។

ចូលសិក្ខាសាលាថ្នាក់ជាតិស្តីពី ការលើកកម្ពស់សិទ្ធិអំណាចផ្នែកសេដ្ឋកិច្ចសម្រាប់ស្ត្រី ។ ចូលរួមសិក្ខាសាលាស្តីពី ការគណនាតំលៃនៃការបញ្ជ្រាបយេនឌ័រ ដើម្បីបន្ស៊ាំនឹងការប្រែប្រួលអាកាសធាតុ និងភាពធន់របស់ស្ត្រីក្រីក្រនៅជនបទតាមរយៈការលើកកម្ពស់អនាម័យ និងការប្រើប្រាស់ទឹកស្អាត និងចុះប្រមូលទិន្នន័យដើមគ្រាបែងចែកតាមភេទ ។ បានរៀបចំវគ្គសិក្ខាសាលាផ្សព្វផ្សាយ ស្តីពី លើកកម្ពស់ការយល់ដឹងពីជំងឺអេដស៍ កាមរោគ និងសុខភាពបន្តពូជ ដល់ប្រជាពលរដ្ឋបានចំនួន ០៣ វគ្គ នៅខេត្តត្បូងឃ្មុំ ខេត្តកំពង់ឆ្នាំង និងខេត្តបាត់ដំបង មានសមាសភាពចូលរួមសរុប ចំនួន ១៨៤នាក់ ស្ត្រី ៨០នាក់ ។ ចូលរួមកិច្ចប្រជុំស្តីពី ការប៉ះពាល់នៃគ្រឿងញៀនទៅលើការរីករាលដាលនៃការឆ្លងមេរោគអេដស៍ ជំងឺអេដស៍ ។ ជាលទ្ធផលនៃការអនុវត្តថវិកាកម្មទាំង ៣ ក្រសួងសម្រេចបាន ៩៨% នៃផែនការឆ្នាំ២០១៨ ។

## II. លទ្ធផលសម្រេចបានក្នុងនីតិកាលទី៥ និងបញ្ហាប្រឈមសម្រាប់ឆ្នាំ២០១៩

ក្នុងនីតិកាលទី៥ នៃរដ្ឋសភាក្រសួងអភិវឌ្ឍន៍ជនបទបានអនុវត្តប្រកបដោយជោគជ័យលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទ ឆ្នាំ២០១៤-២០១៨ ដោយបាននាំមកនូវភាពប្រែប្រួលជាវិជ្ជមានអំពីស្ថានភាពជីវភាពរស់នៅ សុខភាព អនាម័យ និងសេវាសាធារណៈផ្សេងៗដោយសុខដុមរម្យនាក្នុងសង្គមគ្រួសារនៅតំបន់ជនបទ ។ សមិទ្ធផលជាច្រើនត្រូវបានរាជរដ្ឋាភិបាល តាមរយៈក្រសួងអភិវឌ្ឍន៍ជនបទផ្តល់ជូនប្រជាជនរួមមាន៖ (១) សាងសង់ផ្លូវថ្មីក្រាលក្រួសក្រហមចំនួន ២,២៧៨គ.ម ជួសជុល

ថែទាំផ្លូវក្រួសក្រហមជាលក្ខណៈខួប និងប្រចាំបានចំនួន ៨,៦២០គ.ម ស្តារឡើងវិញផ្លូវជនបទដែលខូចខាតដោយទឹកជំនន់បានប្រវែង ៥១១គ.ម កែលម្អកម្រាលផ្លូវពីក្រួសក្រហមទៅជាផ្លូវកៅស៊ូពីរជាន់បានចំនួន ១,៦៥០គ.ម សាងសង់លូមូល លូជ្រុងគ្រប់ប្រភេទបានចំនួន ៤,២៧២កន្លែង សាងសង់ស្ពានបេតុង និងសំណង់បង្ហៀរទឹកសរុបចំនួន ១៩៩កន្លែង ដាំកូនឈើអមសងខាងផ្លូវការពារទប់ទល់នឹងការប្រែប្រួលអាកាសធាតុបានចំនួន ២១៧,២៩២ដើម សាងសង់ទីទួលសុវត្ថិភាពសម្រាប់បង្ការគ្រោះមហន្តរាយដោយទឹកជំនន់បាន ៣កន្លែង និងសាងសង់អគារមជ្ឈមណ្ឌលសម្រាប់ប្រតិបត្តិការប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គ្រោះបន្ទាន់បានចំនួន ២អគារ ។ (២) ផ្តល់ជូនសេវាផ្គត់ផ្គង់ទឹកស្អាត អប់រំសុខភាព អនាម័យក្នុងការលើកកម្ពស់លក្ខខណ្ឌនៃការរស់នៅរបស់ប្រជាជនជនបទបានល្អប្រសើរ ដើម្បីឈានទៅសម្រេចបាននូវទស្សនវិស័យរបស់រាជរដ្ឋាភិបាល ដែលបានកំណត់ថា " ឆ្នាំ២០២៥ ប្រជាពលរដ្ឋនៅសហគមន៍ជនបទគ្រប់រូបត្រូវមានការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យគ្រប់គ្រាន់ និងរស់នៅក្នុងបរិស្ថានដែលមានអនាម័យប្រកបដោយនិរន្តរភាព ដាក់ស្តែងក្នុងការអនុវត្តផែនការអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាឆ្នាំ២០១៥ ក្រសួងបានលើកផែនការកំណត់យកការផ្គត់ផ្គង់ទឹកស្អាតជនបទ៥០%និងអនាម័យជនបទ ៣០%នៅក្នុងឆ្នាំ២០១៥ តែជាលទ្ធផលក្រសួងបានសម្រេចផ្គត់ផ្គង់សេវាទឹកស្អាតជនបទបាន៥០.៣% និងសេវាអនាម័យជនបទបាន ៥៣.៧% លើសផែនការដែលបានកំណត់។ ក្នុងការកំណត់គោលដៅថ្មី ៦០% ទាំងសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ សម្រាប់អនុវត្តផែនការយុទ្ធសាស្រ្តជាតិស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យជនបទឆ្នាំ ២០១៤-២០១៨ ក្រសួងអាចនឹងសម្រេចលើសគោលដៅនៅក្នុងឆ្នាំ២០១៨ នេះបើយោងតាមទិន្នន័យ(CSEC 2017)ចុងក្រោយក្នុងឆ្នាំ២០១៧ អត្រាគ្របដណ្តប់នៃការផ្គត់ផ្គង់ទឹកស្អាតជនបទបានកើនដល់៥៨.៧%និងអនាម័យបានកើនដល់ ៧១.២% រួចទៅហើយ ។ (៣) ផ្តល់ជូនការងារ មុខរបរអាជីវកម្ម សហគ្រាសខ្នាតតូច និងសកម្មភាពសេដ្ឋកិច្ចជាច្រើនទៀតដើម្បីផ្លាស់ប្តូរលក្ខខណ្ឌជីវិត (Life Condition Change) របស់ប្រជាជនជនបទឲ្យបានកាន់តែល្អប្រសើរជាងមុន ។ ក្រសួងបានអនុវត្តវិធីសាស្រ្តអភិវឌ្ឍន៍ជនបទចម្រុះ ( Integrated Rural Development ) ជាច្រើនវិស័យដូចជា បង្កើតសិប្បកម្ម សហគ្រិនខ្នាតតូច មធ្យម កសិកម្ម សុខាភិបាល ឡូជីស្ទីក បរិស្ថាន បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈមូលដ្ឋាន ឥណទាន និង វិស័យដទៃទៀត ក្នុងគោលដៅជំរុញការអភិវឌ្ឍជនបទ ប្រកបដោយសក្តានុពល និងនវានុវត្តន៍ ។ ក្រសួងបានបណ្តុះបណ្តាលមន្ត្រីសរុបចំនួន ១៨ ៣០៨នាក់ ក្នុងនោះការបណ្តុះបណ្តាលជំនាញផ្សេងៗក្នុងប្រទេសបានចំនួន ១៧,៩៧៥នាក់ ក្រៅប្រទេសបានចំនួន ៣៣៣នាក់ ។ មជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈមូលដ្ឋានក្នុងខេត្តគោលដៅចំនួន៨គឺ ខេត្តស្វាយរៀង ព្រៃវែង តាកែវ កំពង់ស្ពឺ កំពង់ចាម បាត់ដំបង

ពោធិ៍សាត់ និងកំពត បានវគ្គបណ្តុះបណ្តាលជំនាញផ្សេងៗរួមមាន ៖ ជំនាញកាត់ដេរ ជួសជុលកុំព្យូទ័រ ជួសជុលម៉ាស៊ីនដេរ គ្រឿងយន្តកសិកម្ម ធ្វើសង្ហារឹម អ៊ុតសក់ កាត់សក់ ។ល។ សរុបបានចំនួន ៤០ ៣៣០នាក់ ។ ក្រសួងបានចេញលិខិតទទួលស្គាល់ អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិចបានចំនួន ១៤៣សហគមន៍ ក្នុងចំណោម ៤៥៥សហគមន៍ជនជាតិភាគតិចដើម្បីងាយស្រួលគ្រប់គ្រង ថែរក្សាអភិវឌ្ឍន៍ និងអភិរក្ស ។

បញ្ហាប្រឈមជាចម្បងក្នុងវិស័យអភិវឌ្ឍន៍ជនបទរួមមាន ការកើនឡើងយ៉ាងគំហុកនូវតម្រូវការប្រើប្រាស់ផ្លូវជនបទ ការដឹកជញ្ជូនលើសទម្ងន់ច្បាប់កំណត់ ការអភិវឌ្ឍនៅទីដាច់ស្រយាល ការកើនឡើងនៃការធ្វើចំណាកស្រុកស្វែងរកការងារ ចំណេះជំនាញមូលដ្ឋាននៅពុំទាន់សមស្របអាចបង្កើតការងារ ស្វែងរកការងារធ្វើក្នុងបរិបទបច្ចុប្បន្ន ការយល់ដឹងពីបញ្ហាសុខភាពអនាម័យនៅខ្វះចន្លោះជាច្រើន ពិសេសនៅតំបន់ជនបទដាច់ស្រយាល ការងារយេនឌ័រ និងជនជាតិដើមភាគតិចជាដើម ។ កត្តាប្រែប្រួលអាកាសធាតុនៅតែជាបញ្ហាប្រឈមមួយផងដែរ សម្រាប់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ជនបទ និងហេដ្ឋរចនាសម្ព័ន្ធរូបវន្តដទៃទៀត ពិសេសពាក់ព័ន្ធដល់ការខ្វះខាតទឹកប្រើប្រាស់ និងទឹកបរិភោគនៅរដូវប្រាំង ។ ថវិកាសម្រាប់យកទៅអភិវឌ្ឍន៍នៅមានកម្រិតនៅឡើយសម្រាប់ការស្តាបនា សាងសង់ផ្លូវថ្នល់ដែលមានប្រវែងជាង ៤៥,២០០គ.ម ដែលជាតម្រូវការចាំបាច់របស់ប្រជាពលរដ្ឋជនបទនៅទូទាំងប្រទេស ជាពិសេសនៅតំបន់ដាច់ស្រយាល ។ ការចូលរួមរបស់ស្ត្រីក្នុងការងារអភិវឌ្ឍន៍ក៏ទាមទារឲ្យមានការជំរុញ និងយកចិត្តទុកដាក់បន្ថែមទៀត។

## ២.១.ទិដ្ឋភាពគោលនយោបាយអាទិភាពក្នុងវិស័យអភិវឌ្ឍន៍ជនបទ ឆ្នាំ២០២០-២០២២

ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ ក្រសួងអភិវឌ្ឍន៍ជនបទបានដាក់ចេញជាក្របខណ្ឌយុទ្ធសាស្ត្ររយៈពេល ៥ ឆ្នាំ ២០១៩-២០២៣ បន្ត ដើម្បីលើកកម្ពស់គុណភាព និងគុណតម្លៃនៃជីវិតរបស់ប្រជាជនជនបទតាមរយៈយន្តការអាទិភាព ០៤ ចំនុច ៖ **ទី១.** *អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងគមនាគមន៍* ដោយបង្កើនការស្តាបនា ជួសជុល លើកកម្រិតហេដ្ឋារចនាសម្ព័ន្ធរូបវន្ត គមនាគមន៍ និងសេវាសម្រាប់សាធារណៈជន ដូចជាផ្លូវជនបទ សំណង់សិល្បការ្យផ្សេងៗ ដើម្បីដល់ការដឹកជញ្ជូន និងសេវាសាធារណៈផ្សេងៗទៀតនៅតំបន់ជនបទ ជាពិសេសតំបន់ដែលមានសក្តានុពលសេដ្ឋកិច្ចខ្ពស់ ។ **ទី២.** *កែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ* ដែលផ្តោតសំខាន់លើការលើកកម្ពស់សុខភាព អនាម័យ ការអប់រំប្រជាជនយល់ដឹងពីការរស់នៅស្អាត ផឹកស្អាត ភូមិឃុំមានបរិស្ថានរស់នៅស្អាត ភូមិឃុំមានសុវត្ថិភាព សំដៅជំរុញលក្ខខណ្ឌនៃការរស់នៅតាមតំបន់ជនបទឲ្យបានល្អប្រសើរ តាមរបៀបរស់នៅបែបទំនើបនៅតំបន់ជនបទ (Rural Lifestyle Condition) ។ **ទី៣.** *ពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ* មានគោលបំណងរួមចំណែកក្នុងការចូលរួមដោះស្រាយបញ្ហាជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជននៅជនបទ

ដែលជាកត្តាសំខាន់បំផុតពុំអាចខ្វះបានក្នុង ។ ការបង្កើនប្រាក់ចំណូលប្រចាំថ្ងៃរបស់ប្រជាជននៅជនបទត្រូវបានក្រសួងយកចិត្តទុកដាក់យ៉ាងខ្លាំង ក្នុងការគៀគរកជំនួយឧបត្ថម្ភសម្រាប់អនុវត្តកម្មវិធីនេះឲ្យទទួលបានជោគជ័យដើម្បីរំចំណែកជំរុញការកាត់បន្ថយភាពក្រីក្រនៅជនបទ ។ ក្រសួងមានគោលដៅបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈមូលដ្ឋានឲ្យបានកាន់តែច្រើនឡើងថែមទៀត ពិសេសមជ្ឈមណ្ឌលមូលដ្ឋានចល័តនៅតំបន់ជនបទដាច់ស្រយ៉ាល ដើម្បីបង្កិតសេវាផ្តល់ជំនាញមូលដ្ឋានកាន់តែទៅជិតភូមិ ឃុំ ស្រុករបស់ប្រជាជន ដែលបង្កលក្ខណៈឲ្យប្រជាជនមានលទ្ធភាពចូលរួមកាន់តែច្រើនឡើងៗមកទទួលយកជំនាញមួយយ៉ាងតិច សម្រាប់យកទៅប្រកបរបរចិញ្ចឹមជីវិត ដែលទទួលបានប្រាក់ចំណូលខ្ពស់ជាងមុន ។ ជាងនេះទៀត ក្រសួងក៏មានគោលដៅសាងសង់ផ្សារជនបទដែលជាកន្លែងដោះដូរទំនិញដែលជាផលិតផលក្នុងស្រុកដូចជា ផលិតផលកសិកម្ម សិប្បកម្ម និងសេវកម្មផ្សេងៗទៀតដែលប្រជាជនផលិតបាន ។ ក្រៅពីនេះ ក្រសួងនឹងចូលរួមផ្សព្វផ្សាយឲ្យប្រជាជនចូលរួមយ៉ាងសកម្មក្នុងកម្មវិធីនេះ ព្រមទាំងផ្តល់ការលើកទឹកចិត្តជាកម្មវិធីដែលមានអត្រាការប្រាក់ទាបធ្វើជាទុនបង្កើតមុខរបរ និងចលនាឲ្យប្រជាជនគាំទ្រផលិតផលក្នុងស្រុកដើម្បីចូលរួមលើកទឹកចិត្តដល់ផលិតផលរបស់ខ្មែរយើង ។ **ទី៤.** *សេវាគាំទ្ររដ្ឋបាល ហិរញ្ញវត្ថុ និងកិច្ចការទូទៅ* ជាកម្មវិធីបង្កើតឡើងសម្រាប់ផ្តល់សេវាផ្សេងៗគាំទ្រដល់កម្មវិធីទាំង៣ ខាងលើឲ្យទទួលបានជោគជ័យ ។ កម្មវិធីនេះ មានគោលបំណងបង្កើនប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ក្នុងការប្រើប្រាស់ថវិកាឲ្យចំគោលដៅ បម្រើដល់គោលបំណងគោលនយោបាយរបស់ក្រសួងក៏ដូចជាគោលនយោបាយរបស់រាជរដ្ឋាភិបាលផងដែរ ។ ការអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការត្រូវបានដាក់បញ្ចូលក្នុងកម្មវិធីនេះផងដែរ ដែលសំដៅដល់ការពង្រឹងសមត្ថភាពមន្ត្រីក្នុងការអនុវត្តគម្រោងផែនការថវិកាកម្មវិធីប្រចាំឆ្នាំឲ្យទទួលបានជោគជ័យ ។

## ២.២.យុទ្ធសាស្ត្រ

ដើម្បីសម្រេចបានទិសដៅជាយុទ្ធសាស្ត្រខាងលើ ក្រសួងអភិវឌ្ឍន៍ជនបទបានកំណត់យុទ្ធសាស្ត្រអាទិភាពចំនួន ០៤ ដូចខាងក្រោម៖

- យុទ្ធសាស្ត្រទី១៖ ស្តាបនា លើកកម្រិតហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងគមនាគមន៍នៅជនបទ
- យុទ្ធសាស្ត្រទី២៖ កែលម្អលក្ខខណ្ឌនៃការរស់នៅរបស់ប្រជាជននៅតាមសហគមន៍ជនបទ
- យុទ្ធសាស្ត្រទី៣៖ ជំរុញពិពិតកម្មសកម្មភាពអភិវឌ្ឍន៍សេដ្ឋកិច្ចគ្រួសារនៅជនបទ
- យុទ្ធសាស្ត្រទី៤៖ សម្របសម្រួលគាំទ្រដល់ការងាររដ្ឋបាល ហិរញ្ញវត្ថុ និងកិច្ចការទូទៅក្នុងក្រសួង

## ២.៣. គោលបំណងគោលនយោបាយ

ដើម្បីរួមចំណែកអនុវត្តគោលនយោបាយតាមវិស័យ ពិសេសគោលនយោបាយរួមរបស់រាជរដ្ឋាភិបាល ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព សំដៅសម្រេចឲ្យបាននូវគោលដៅកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់លក្ខខណ្ឌរស់នៅ របស់ប្រជាជនជនបទឲ្យបានល្អប្រសើរ ក្រសួងអភិវឌ្ឍន៍ជនបទមានគោលបំណងគោលនយោបាយដូចខាងក្រោម៖

| គោលបំណងគោលនយោបាយ | បម្រើឲ្យគោលដៅយុទ្ធសាស្ត្រណាមួយ និងវិធានការគោលនយោបាយអ្វីខ្លះរបស់រាជរដ្ឋាភិបាល | ស្ថិតក្នុងវិស័យណាមួយ នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ ២០១៩-២០២៣ |
|---|---|---|
| លើកកម្ពស់គុណភាព និងគុណតម្លៃនៃជីវិតរស់នៅរបស់ប្រជាជនជនបទ ប្រកបដោយបរិយាប័ន្ន ទាំងផ្នែកសេដ្ឋកិច្ច សង្គម និងវប្បធម៌។ | • យុទ្ធសាស្ត្រចតុកោណជំណាក់កាលទី៤ ចតុកោណទី៤ មុំទី១ ការលើកកម្ពស់កសិកម្ម និងការអភិវឌ្ឍជនបទ<br>• ចតុកោណទី២ ការធ្វើពិពិធកម្មសេដ្ឋកិច្ច មុំទី១ ការកែលម្អប្រព័ន្ធឡូជីស្ទីក ,លើកកម្ពស់ការតភ្ជាប់ផ្នែកដឹកជញ្ជូន ថាមពល និងឌីជីថល<br>• ចតុកោណទី៣ ការលើកស្ទួយវិស័យឯកជន និងការងារ<br>• ចតុកោណទី១ ការអភិវឌ្ឍធនធានមនុស្ស | • ហេដ្ឋារចនាសម្ព័ន្ធ ការតភ្ជាប់ផ្នែកដឹកជញ្ជូន<br>• បង្កើតការងារ សហគ្រាស និងមុខរបរ<br>• បរិស្ថាន និងការប្រែប្រួលអាកាសធាតុ<br>• អភិវឌ្ឍន៍ធនធានមនុស្ស ពង្រឹងសមត្ថភាព |

## III. ការរៀបចំកម្មវិធី

ដើម្បីអនុវត្តយុទ្ធសាស្ត្រទាំង ៤ ដូចបានរៀបរាប់ខាងលើឲ្យមានប្រសិទ្ធភាព ក្រសួងបានប្រែក្លាយយុទ្ធសាស្ត្រទាំងនេះទៅជាកម្មវិធីសម្រាប់យកទៅអនុវត្តជាក់ស្តែង ៖

**កម្មវិធីទី១ ៖ អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងគមនាគមន៍**

**កម្មវិធីទី២ ៖ កែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ**

**កម្មវិធីទី៣ ៖ ពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ**

**កម្មវិធីទី៤ ៖ សេវាគាំទ្ររដ្ឋបាល ហិរញ្ញវត្ថុ និងកិច្ចការទូទៅ**

### ១-កម្មវិធីទី១ ៖ អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងគមនាគមន៍

ក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ការកសាងសេដ្ឋកិច្ចជាតិ ការអភិវឌ្ឍសង្គមត្រូវបានផ្សារភ្ជាប់គ្នាយ៉ាងជិតស្និទ្ធទៅនឹងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ សម្រាប់បម្រើដល់ការដឹកជញ្ជូន Logistic និងទំនាក់ទំនងសាធារណៈជាបណ្តាញ Network ដើម្បីផ្លាស់ប្តូរទំនិញ ផលិតផលកសិកម្ម ពាណិជ្ជកម្ម សេវាកម្ម ។ល។ រវាងទីក្រុង និងជនបទ ឬរវាងជនបទនិងជនបទដើម្បីស្វែងរកទីផ្សារលក់ផលិផលកសិផលដែលជាតម្រូវការប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋក្នុងប្រទេស ។ ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ជនបទ កំពុងដើរតួនាទីយ៉ាង

សំខាន់ក្នុងការភ្ជាប់ទំនាក់ទំនងរវាងអ្នកផលិតនឹងឈ្មួញកណ្ដាល ដែលជាកាតាលីករសំខាន់ក្នុងការជំរុញឲ្យមានកំណើនសេដ្ឋកិច្ចជាតិ ពិសេសនៅតំបន់ជនបទ ។ ហេដ្ឋារចនាសម្ព័ន្ធរូបវន្តជនបទមានច្រើនដូចជា ៖ ផ្លូវគមនាគមន៍ សាលារៀន មន្ទីរពេទ្យ សំណង់ធារាសាស្ត្រ ស្ពាន អណ្ដូងទឹក ស្រះទឹក ផ្សារជនបទ អគ្គិសនី បណ្ដាញទឹកស្អាត បង្គន់អនាម័យសាធារណៈ បង្គន់អនាម័យឯកជន ។ល។ ដែលជាតម្រូវការប្រចាំថ្ងៃរបស់ប្រជាជនជនបទ ។ ក្នុងបណ្ដាហេដ្ឋារចនាសម្ព័ន្ធសាធារណៈទាំងអស់នេះ ក្រសួងអភិវឌ្ឍន៍ជនបទទទួលខុសត្រូវតែលើ ផ្លូវជនបទ សំណង់ស្ពាន សំណង់ផ្សារ ស្រះទឹក ប្រឡាយទឹកខ្នាតតូច អណ្ដូងទឹក ប្រព័ន្ធចែកចាយទឹកតាមទុយោ តែប៉ុណ្ណោះ ។ ក្រសួងអភិវឌ្ឍន៍ជនបទនឹងបន្តស្ដាបនា និងកែលម្អផ្លូវជនបទចែកចេញជាបីប្រភេទធំៗមាន ផ្លូវក្រាលក្រួសក្រហម ផ្លូវក្រាលកៅស៊ូពីរជាន់ និងផ្លូវបេតុងដែលអាចធន់នឹងការដឹកជញ្ជូន និងមានភាពធន់នឹងការប្រែប្រួលអាកាសធាតុ ដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងវប្បធម៌នៅតាមជនបទ ។ ក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២០-២០២២ ខាងមុខនេះ ក្រសួងមានសកម្មភាពអាទិភាពសំខាន់ៗដូចខាងក្រោម៖

- បន្តការងារសាងសង់ ជួសជុល ថែទាំផ្លូវជាលក្ខណៈខួប លើផ្លូវជនបទកម្រាលក្រួសក្រហម
- បន្តការងារសាងសង់ និងកែលម្អកម្រាលផ្លូវពីក្រួសក្រហមទៅជាផ្លូវក្រាលកៅស៊ូពីរជាន់
- បន្តសាងសង់ផ្លូវក្រាលបេតុងនៅតំបន់ដែលរងនូវផលប៉ះពាល់ការប្រែប្រួលអាកាសធាតុខ្លាំង
- បន្តរៀបចំដំណើរការផ្ទេរមុខងារការថែទាំផ្លូវជនបទជាលក្ខណៈប្រចាំទៅឲ្យថ្នាក់ក្រោមជាតិ
- សាងសង់ប្រព័ន្ធធារាសាស្ត្រខ្នាតតូច ដូចជាប្រឡាយស្រោចស្រព ទំនប់ទឹក ស្ពាន សំណង់ស្នាក់ទឹក និងសំណង់សិល្បការ្យផ្សេងៗ
- បន្តអភិវឌ្ឍន៍ប្រព័ន្ធគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌ និងមូលដ្ឋានទិន្នន័យផ្លូវជនបទនៃព្រះរាជាណាចក្រកម្ពុជាឱ្យកាន់តែមានប្រសិទ្ធិភាពខ្ពស់ ដែលអាចមានលទ្ធភាពក្នុងកសាងផែនការកំណត់អាទិភាពខ្សែផ្លូវ និងកសាងផែនការថវិកាសម្រាប់ការងារស្ដាបនា ជួសជុល និងថែទាំផ្លូវជនបទ

កម្មវិធីទី១ មានអនុកម្មវិធីចំនួន ៤ និងចង្កោមសកម្មភាពចំនួន ៨ និងសកម្មភាព ១៥០ ដូចខាងក្រោម៖

### ១.១.អនុកម្មវិធីទី១ ៖ ការជួសជុលថែទាំ និងរក្សាគុណភាពផ្លូវជនបទ

- ១.១.១.ច.សទី១៖ការទាំផ្លូវជាលក្ខណៈខួប
- ១.១.២.ច.សទី២៖ការទាំផ្លូវជាលក្ខណៈប្រចាំ
- ១.១.៣.ច.ស.ទី៣៖ការជួសជុលផ្លូវជាលក្ខណៈបន្ទាន់

### ១.២.អនុកម្មវិធីទី២ ៖ ការពង្រីកវិសាលភាពនៃការស្ដាបនា លើកកម្រិតហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ

- ១.២.១.ច.សទី១ ៖ ការស្ថាបនា និងកែលម្អផ្លូវជនបទ(ជំពូក២១)
- ១.២.២.ច.សទី២ ៖ ការស្ថាបនាសំណង់សិល្បការ្យ
- ១.២.៣.ច.សទី៣ ៖ ការរាប់ចំនួនចរាចរណ៍

**១.៣.អនុកម្មវិធីទី៣ ៖ ការរៀបចំបញ្ជីសារពើភណ្ឌ និងមូលដ្ឋានទិន្នន័យផ្លូវជនបទ**

- ១.៣.១.ច.សទី១ ៖ ការរៀបចំបញ្ជីសារពើភណ្ឌផ្លូវជនបទ
- ១.៣.២.ច.សទី២ ៖ ការរៀបចំផែនទីផ្លូវជនបទ

**១.៤.អនុកម្មវិធីទី៤ ៖ ការផ្តល់សេវាហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តជនបទ ដោយមន្ទីរជំនាញ ២៥**

- ១.៤.១.ស.កទី១ ៖ ការងារថែទាំផ្លូវជនបទជាលក្ខណៈប្រចាំ
- ១.៤.២.ស.កទី២ ៖ ការងារថែទាំ ជួសជុលស្ពាន និងហេដ្ឋារចនាសម្ព័ន្ធជនបទ
- ១.៤.៣.ស.កទី៣ ៖ ការងារថែទាំផ្លូវទប់ទល់នឹងការប្រែប្រួលអាកាសធាតុ(ដាំកូនឈើ)
- ១.៤.៤.ស.កទី៤ ៖ ការរាប់ចំនួនចរាចរណ៍យានយន្ត
- ១.៤.៥.ស.កទី៥ ៖ ការសាងសង់ទីទួលសុវត្ថិភាព
- ១.៤.៦.ស.កទី៦ ៖ ត្រួតពិនិត្យការដឹកជញ្ជូនលើសទំងន់លើផ្លូវជនបទ

## ២.កម្មវិធីទី២ ៖ កែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ

ដើម្បីជានាលើកកម្ពស់គុណភាព និងគុណតម្លៃនៃជីវិតរស់នៅរបស់ប្រជាជន ជនបទឲ្យបានល្អប្រសើរក្រសួងអភិវឌ្ឍន៍ជនបទបានសម្រួចទិសដៅរបស់ខ្លួន ដើម្បីសម្រេចឲ្យបាននូវទស្សនវិស័យនៃគោលនយោបាយដែលបានកំណត់ថា "*ឆ្នាំ២០២៥ ប្រជាពលរដ្ឋនៅជនបទគ្រប់រូបត្រូវមានការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យគ្រប់គ្រាន់ និងរស់នៅក្នុងបរិស្ថានដែលមានអនាម័យប្រកបដោយនិរន្តរភាព*"។ ដើម្បីឈានទៅសម្រេចបាននូវទស្សនវិស័យនេះ ក្រសួងបានកំណត់យកទិសដៅរយៈពេលមធ្យមនូវអត្រាគ្របដណ្តប់ ៩០% ទាំងទឹកស្អាត និងអនាម័យនៅឆ្នាំ២០២៣ នៅក្នុងផែនការ សកម្មភាពជាតិជំហ៊ានទី២ របស់ខ្លួន។ ក្រសួងបានផ្តោតការយកចិត្តទុកដាក់លើវិធានការ ៣ សំខាន់ៗ ស្តីពីការប្រើប្រាស់បង្គន់ ការលាងសម្អាតដៃនឹងសាប៊ូ និងការបរិភោគទឹកស្អាត ។សកម្មភាពជាអាទិភាពដូចខាងក្រោម៖

- ធ្វើការត្រួតពិនិត្យប្រសិទ្ធភាពនៃការអនុវត្តផែនការសកម្មភាពជាតិស្តីពី ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទនៅជំហានទី១ ឆ្នាំ២០១៤-២០១៨ និងរៀបចំផែនការសកម្មភាពជាតិស្តីពីការលើសកំពស់ការផ្គត់ផ្គង់ទឹកស្អាត សុខភាព និងការលើកកំពស់ អនាម័យនៅជនបទជំហានទី២ ឆ្នាំ២០១៩-២០២៣

- ពង្រឹងប្រព័ន្ធតាមដាន ត្រួតពិនិត្យលទ្ធផល ពង្រឹងសមត្ថភាពស្ថាប័ន កៀរគរធនធាន និងបន្តពង្រឹងកិច្ចសហការរវាងដៃគូពាក់ព័ន្ធទាំងអស់ ធានាឲ្យបាននូវសុខដុមនីយកម្ម កម្មវិធី និងគម្រោងទាំងអស់ឲ្យស្របតាមផែនការសកម្មភាពជាតិ បន្តបង្កើន និងជំរុញការអភិវឌ្ឍវិស័យផ្គត់ផ្គង់ទឹកស្អាត សុខភាព និងអនាម័យសម្រាប់ប្រើប្រាស់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជនប្រកបដោយគុណភាព និងប្រសិទ្ធភាព
- ពង្រីកសកម្មភាពការផ្គត់ផ្គង់ទឹកស្អាត សុខភាព និងការលើកកម្ពស់អនាម័យជនបទ
- សាងសង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តជនបទដទៃទៀតដូចជា ស្រះទឹក អណ្តូងទឹក ប្រព័ន្ធចែកចាយទឹកតាមទុយោខ្នាតតូចសហគមន៍ អាងដំកល់ទឹក ពាងយក្ស អាងត្រងទឹកភ្លៀង ធុងចម្រោះ បង្គន់អនាម័យ ។ល។
- បន្តរៀបចំដំណើរការផ្ទេរមុខងារការងារថែទាំ និងជួសជុលអណ្តូង សាងសង់បង្គន់អនាម័យសាធារណៈទៅថ្នាក់ក្រោមជាតិ
- បន្តផ្តល់ជំនួយបច្ចេកទេសដល់ក្រុមប្រឹក្សាឃុំ និងគណៈកម្មាធិការអភិវឌ្ឍន៍ភូមិបច្ចេកទេសថែទាំ និងជួសជុលអណ្តូង សាងសង់បង្គន់អនាម័យសាធារណៈ
- បន្តអប់រំផ្សព្វផ្សាយដល់ប្រជាជនជនបទឲ្យយល់ដឹងពីបរិស្ថាន និងប្រតិបត្តិអនាម័យ
- ពង្រីកការតបណ្តាញទឹកស្អាតទទួលទាន នៅសហគមន៍ជនបទ
- លុបបំបាត់ការបន្ទោបង់ពាសវាលពាសកាលដោយពង្រីកពីភូមិទៅឃុំ ពីឃុំទៅស្រុកពីស្រុកទៅខេត្ត
- យ៉ាងហោចណាស់ខេត្តចំនួន ៥ នឹងបញ្ឈប់ការបន្ទោបង់ពាសវាលពាសកាល
- ជំរុញការផ្លាស់ប្តូរទម្លាប់នៃការប្រើប្រាស់បង្គន់ ការលាងដៃនឹងសាប៊ូ និងការបរិភោគទឹកស្អាត

ដើម្បីសម្រេចគោលដៅខាងលើ ក្រសួងបានកំណត់យកអនុកម្មវិធីចំនួន ៥ និងចង្កោមសកម្មភាពអាទិភាព ចំនួន ១១ និងសកម្មភាពចំនួន ២០០ ដូចខាងក្រោម៖

**២.១.អនុកម្មវិធីទី១ ៖ កែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ**

- ២.១.១.ច.សទី១ ៖ ការសាងសង់អណ្តូងទឹកធន់នឹងការប្រែប្រួលអាកាសធាតុ
- ២.១.២.ច.សទី២ ៖ ការសាងសង់ប្រភពទឹកស្អាតជនបទ
- ២.១.៣.ច.សទី៣ ៖ ការសាងសង់ ស្តារប្រព័ន្ធស្រោចស្រពខ្នាតតូច
- ២.១.៤.ច.សទី៤ ៖ ការផ្គត់ផ្គង់សេវាទឹកស្អាត និងអន្តរាគមន៍បន្ទាន់លើគ្រោះមហន្តរាយ

**២.២.អនុកម្មវិធីទី២ ៖ បង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ទឹកស្អាតជនបទ**

- ២.២.១.ច.សទី១ ៖ បណ្តុះបណ្តាលបច្ចេកទេសថែទាំ និងជួសជុលអណ្តូងទឹក
- ២.២.២.ច.សទី២ ៖ អប់រំប្រជាពលរដ្ឋយល់ដឹងពីការប្រើប្រាស់ទឹកស្អាត
- ២.២.៣.ច.សទី៣ ៖ ប្រារព្ធទិវាទឹកពិភពលោក

- ២.២.៤.ច.សទី៤ ៖ រៀបចំផែនការសុវត្ថភាពទឹក
- ២.២.៥.ច.សទី ៥ ៖ តាមដាន ត្រួតពិនិត្យការងារទឹកស្អាតជនបទ

### ២.៣.អនុកម្មវិធីទី ៣ ៖ ការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តអនាម័យជនបទ

- ២.៣.១.ច.សទី១ ៖ ការសាងសង់បង្គន់អនាម័យសម្រាប់ប្រជាជនជនបទ
- ២.៣.២.ច.សទី២ ៖ ការស្រង់ទិន្នន័យបញ្ជីសារពើភ័ណ្ឌបង្គន់អនាម័យ

### ២.៤.អនុកម្មវិធីទី៤ ៖ ការលើកកម្ពស់ការរស់នៅស្អាត ការអប់រំសុខភាព និងអនាម័យជនបទ

- ២.៤.១.ច.សទី១៖ ការពង្រឹងសមត្ថភាពស្ថាប័នក្នុងការលើកកម្ពស់ការរស់នៅស្អាត និងអនាម័យជនបទ
- ២.៤.២.ច.សទី២ ៖ បង្កើនការប្រើប្រាស់បង្គន់អនាម័យដែលមានការកែលម្អប្រកបដោយនិរន្តភាព
- ២.៤.៣.ច.សទី៣ ៖ លើកកម្ពស់ការផ្លាស់ប្តូរឥរិយាបថប្រតិបត្តិ ការរស់នៅស្អាត និង អនាម័យ
- ២.៤.៤.ច.សទី៤ ៖ វិធានការលើកកម្ពស់សុខភាព ការរស់នៅស្អាត និងអនាម័យជនបទ
- ២.៤.៥.ច.សទី៥ ៖ ការងារអប់រំ ជំងឺឆ្លង និងសុខភាពផ្លូវភេទ

### ២.៥. អនុកម្មវិធីទី៥ ៖ ការផ្តល់សេវាសុខភាព និងលក្ខខ័ណ្ឌនៃការរស់នៅសម្រាប់សាធារណៈជនដោយមន្ទីរជំនាញ ២៥

- ២.៥.១.ស.កទី១ ៖ ការផ្សព្វផ្សាយ និងអប់រំសហគមន៍ពីលក្ខខណ្ឌនៃការរស់នៅស្អាត
- ២.៥.២.ស.កទី២ ៖ បង្កើនសហគមន៍បញ្ឈប់បន្ទោរបង់ពាសវាលពាសកាល (ODF)
- ២.៥.៣.ស.កទី៣ ៖ ប្រារព្វទិវាលាងសម្អាតដៃពិភពលោកតាមខេត្ត
- ២.៥.៤.ស.កទី៤ ៖ ប្រារព្វទិវាអនាម័យ ១៣ វិច្ឆិកាតាមខេត្ត
- ២.៥.៥.ស.កទី៥ ៖ ផ្សព្វផ្សាយការប្រើប្រាស់ បរិភោគទឹកស្អាតដោយសុវត្ថិភាព
- ២.៥.៦.ស.កទី៦ ៖ ការសាងសង់បង្គន់អនាម័យ / បដិភាគសម្ភារៈអនាម័យ
- ២.៥.៧.ស.កទី៧ ៖ ការងារថែទាំ និងជួសជុលអណ្តូងទឹក
- ២.៥.៨.ស.កទី៨ ៖ ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធទឹកស្អាតចម្រុះ

## ៣.កម្មវិធីទី៣ ៖ ពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ

បញ្ហាជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ គឺជាបញ្ហាស្នូលដែលរាជរដ្ឋាភិបាលកំពុងតែខិតខំដោះស្រាយដើម្បីការរស់នៅដោយសុខដុមរមនា ។ ក្រសួងអភិវឌ្ឍន៍ជនបទបានយកចិត្តទុកដាក់និងបានកំណត់អាទិភាពមួយក្នុងចំណោមអាទិភាពទាំងបួនរបស់ក្រសួង ។ ការបង្កើនល្បឿនផលិតកម្មសេដ្ឋកិច្ចជនបទ និងសហគ្រិនភាព គឺដើម្បីគាំទ្រដល់ការបង្កើនប្រាក់ចំណូលតាមគ្រួសារនៅជនបទឲ្យមានជីវភាពប្រសើរឡើងដែលនឹងចូលរួមយ៉ាងសកម្មដល់កម្មវិធីកាត់បន្ថយភាពក្រីក្ររបស់ប្រជាជននៅតាមតំបន់ជនបទ ។ ក្នុងន័យនេះ ក្រសួងនឹងជំរុញការផ្តល់ចំណេះជំនាញ បង្កើតការងារ ផ្តល់ឥណទានសមស្រប រកទីផ្សារ និងបង្កើតបរិយាកាសធុរៈកិច្ចដល់ប្រជាជនប្រកបដោយបរិយាប័ន្ន ដើម្បីធានាបង្កើនស្ថិរភាពប្រាក់ចំណូលតាមគ្រួសារនីមួយៗ ។ សកម្មភាពជាអាទិភាពរួមមាន៖

- បង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញមូលដ្ឋានចល័តនៅតាមសហគមន៍ជនបទឲ្យបានច្រើន
- ចលនាប្រជាជនឲ្យចូលរួមទទួលការបណ្តុះបណ្តាលចំណេះ ជំនាញមូលដ្ឋាន
- ជំរុញឲ្យប្រជាជនក្នុងសហគមន៍ចូលរួមកម្មវិធីបង្កើតអាជីវកម្មខ្នាតតូច និងខ្នាតគ្រួសារ
- រៀបចំកម្មវិធីបណ្តុះបណ្តាលមុខវិជ្ជាទៅតាមតម្រូវការនៅតាមតំបន់នីមួយៗ
- ផ្តល់ជំនាញដល់ជនជាតិដើមភាគតិចក្នុងសហគមន៍ដែលពួកគេរស់នៅ
- ជំរុញបង្កើតទីផ្សារសហគមន៍ តាំងបង្ហាញផលិតផល
- ជំរុញឲ្យប្រជាពលរដ្ឋខ្មែរគាំទ្រ និងប្រើប្រាស់ផលិតផលខ្មែរ
- ជួសជុល និងសាងសង់ផ្សារជនបទដើម្បីដោះដូរផលិតផលក្នុងស្រុក
- បន្តបណ្តុះបណ្តាលស្ត្រីមេផ្ទះ ក្នុងការថែរក្សាទុក និងការកែច្នៃម្ហូបអាហារ និងការរៀបចំសួនដំណាំរបស់គ្រួសារ សម្រាប់បំពេញតម្រូវការ និងបង្កើនប្រាក់ចំណូលគ្រួសារ
- ជំរុញការផ្តល់សេវាប្រាក់កម្ចីដែលមានអាត្រាការប្រាក់សមរម្យ សម្រាប់ការអភិវឌ្ឍសិប្បកម្ម មុខជំនួញ សហគ្រាសខ្នាតតូច និងមធ្យម ជាមួយនឹងការផ្តល់បច្ចេកទេសជំនាញ និងការយល់ដឹងអំពីការបង្កើតមុខរបរ ព្រមទាំងការខិតខំពង្រីកទីផ្សារ ដើម្បីដំណើរការផលិតផលនៅតំបន់ជនបទ
- បន្តគាំទ្រដល់ការបង្កើតធនាគារមិនមែនសាច់ប្រាក់ដូចជា ធនាគារស្រូវ ធនាគារមាន់ ធនាគារជី
- ពង្រឹងគុណភាពនៃការផ្តល់សេវាឥណទានជូនដល់ប្រជាជន
- បង្កើតឲ្យមានក្រុមសន្សំ និងប្រើប្រាស់ថវិកាឲ្យបានត្រឹមត្រូវនិងចំគោលដៅ
- បន្តកំណត់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច
- រៀបចំប្រារព្ធទិវាអន្តរជាតិជនជាតិដើមភាគតិចពិភពលោកប្រចាំឆ្នាំទាំង១៥ ខេត្តគោលដៅ
- បង្កើតមជ្ឈមណ្ឌលអភិរក្ស និងអភិវឌ្ឍន៍ជនជាតិដើមភាគតិច
- បន្តជំរុញការអភិវឌ្ឍនៅតាមតំបន់ដែលមានជនជាតិដើមភាគតិចរស់នៅ ឲ្យកាន់តែមានការរីកចម្រើន ទាំងផ្នែកសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ធានាសិទ្ធិទទួលបាននូវការការពារដោយច្បាប់ និងវិធានការសង្គមនានា ដែលឆ្លើយតបទៅនឹងតម្រូវការចាំបាច់ជាមូលដ្ឋានសម្រាប់ការរស់នៅ

ប្រកបដោយភាពថ្លៃថ្នូរ ព្រមទាំងការគោរពចំពោះទំនៀមទម្លាប់ ប្រពៃណី និងភាសារបស់បងប្អូនជនជាតិដើមភាគតិច

- បន្តអនុវត្តគោលនយោបាយជាតិ ស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច សារាចរណែនាំ នីតិវិធីនៃការកំណត់អត្តសញ្ញាណ និងចុះបញ្ជីសហគមន៍ជនជាតិដើមភាគតិច។

ដើម្បីដោះស្រាយបញ្ហាខាងលើ ក្រសួងបានកំណត់យកអនុកម្មវិធីចំនួន ៦ និងចង្កោមសកម្មភាពចំនួន ២៥ សកម្មភាពចំនួន ១៧៥ នៅក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២០-២០២២ ដូចខាងក្រោម៖

**៣.១.អនុកម្មវិធីទី១ ៖ ជំរុញបង្កើតការងារ និងមុខរបរនៅជនបទ**

- ៣.១.១.ច.សទី១ ៖ ផ្តល់គំនិតបង្កើតអាជីវកម្មខ្នាតតូច និងគ្រួសារ
- ៣.១.២.ច.សទី២ ៖ បង្កើតមជ្ឈមណ្ឌលអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ
- ៣.១.៣.ច.សទី៣ ៖ បង្កើតការកែច្នៃផលិតផលសហគមន៍ជនបទ
- ៣.១.៤.ច.សទី៤ ៖ បង្កើតនិងគាំទ្រសមាគមន៍សន្សំប្រាក់
- ៣.១.៥.ច.សទី៥ ៖ គាំទ្រសកម្មភាពមជ្ឈមណ្ឌលអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ (ជំនួយចិន)
- ៣.១.៦.ច.សទី៦ ៖ បណ្តុះបណ្តាលជំនាញបច្ចេកទេសទីផ្សារ និងការគ្រប់គ្រងអាជីវកម្មខ្នាតតូច
- ៣.១.៧.ច.សទី៧ ៖ បណ្តុះបណ្តាលភាពជាសហគ្រិនភាព

**៣.២.អនុកម្មវិធីទី២ ៖ ការបណ្តុះបណ្តាលជំនាញអាជីព**

- ៣.២.១.ច.សទី១ ៖ រៀបចំកម្មវិធីបណ្តុះបណ្តាលជំនាញអាជីពមូលដ្ឋាន
- ៣.២.២.ច.សទី២ ៖ បង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញចល័ត
- ៣.២.៣.ច.សទី៣ ៖ គាំទ្រសកម្មភាពមជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទកម្ពុជា-កូរ៉េ
- ៣.២.៤.ច.សទី៤ ៖ ការបណ្តុះបណ្តាលជំនាញអាជីពមូលដ្ឋាន

**៣.៣.អនុកម្មវិធីទី៣ ៖ ជំរុញសកម្មភាពសេដ្ឋកិច្ចគ្រួសារនៅជនបទ**

- ៣.៣.១.ច.សទី១ ៖ ជំរុញផ្សព្វផ្សាយផលិតផលសម្រេចសហគមន៍
- ៣.៣.២.ច.សទី២ ៖ ស្វែងរក និងទំនាក់ទំនងទីផ្សារជូនផលិតករសហគមន៍
- ៣.៣.៣.ច.សទី៣ ៖ ការរៀបចំបង្កើតផ្សារជនបទ
- ៣.៣.៣.ច.សទី៤ ៖ គាំទ្រការងារវេណទាននៅសហគមន៍ជនបទ
- ៣.៣.៣.ច.សទី៥ ៖ ពិព័ណ៌ផលិតផលសហគមន៍ជនបទ

**៣.៤.អនុកម្មវិធីទី៤ ៖ ការអភិវឌ្ឍចម្រុះសម្រាប់សហគមន៍ជនបទ**

- ៣.៤.១.ច.សទី១ ៖ ការពង្រឹងសមត្ថភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ)

- ៣.៤.២.ច.សទី២ ៖ ការអភិវឌ្ឍភូមិចម្រុះ
- ៣.៤.៣.ច.សទី៣ ៖ ការលើកកម្ពស់សន្តិសុខស្បៀងជាលក្ខណៈគ្រួសារ
- ៣.៤.៤.ច.សទី៤ ៖ ការគាំទ្រសកម្មភាពអប់រំក្រៅប្រព័ន្ធដល់ប្រជាពលរដ្ឋក្នុងសហគមន៍
- ៣.៤.៥.ច.សទី៥ ៖ ការគាំទ្រសកម្មភាពមជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទកម្ពុជា-កូរ៉េ
- ៣.៤.៦.ច.សទី៦ ៖ ការគាំទ្រសកម្មភាពមជ្ឈមណ្ឌលអភិវឌ្ឍន៍សហគមន៍

**៣.៥.អនុកម្មវិធីទី៥ ៖ ការអភិវឌ្ឍ និងអភិរក្សសហគមន៍ជនជាតិដើមភាគតិច**

- ៣.៥.១.ច.សទី១ ៖ កំណត់អត្តសញ្ញាណជនជាតិដើមភាគតិច
- ៣.៥.២.ច.សទី២ ៖ ពង្រឹង និងអភិវឌ្ឍន៍សហគមន៍ជនជាតិដើមភាគតិច
- ៣.៥.៣.ច.សទី៣ ៖ រៀបចំសហគមន៍គម្រូជនជាតិដើមភាគតិច

**៣.៦.អនុកម្មវិធីទី៦ ៖ ការលើកកម្ពស់កម្រិតជីវភាពរស់នៅតាមជនបទដោយមន្ទីរជំនាញទាំង២៥ រាជធានី ខេត្ត**

- ៣.៦.១.ស.កទី១ ៖ ស្រាវជ្រាវតម្រូវការទីផ្សារក្នុងសហគមន៍មូលដ្ឋាន
- ៣.៦.២.ស.កទី២ ៖ បណ្តុះបណ្តាលជំនាញមូលដ្ឋានអាជីព
- ៣.៦.៣.ស.កទី៣ ៖ បំផុលចលនាមហាជនចូលរួមបង្កើតជំនាញអាជិពផ្ទាល់ខ្លួន
- ៣.៦.៤.ស.កទី៤ ៖ ស្រាវជ្រាវ និងបង្កើតគំនិតច្នៃប្រឌិតអភិវឌ្ឍន៍សហគមន៍មូលដ្ឋាន
- ៣.៦.៥.ស.កទី៥ ៖ ផ្សព្វផ្សាយទិវាជនជាតិដើមភាគតិចប្រចាំឆ្នាំ
- ៣.៦.៦.ស.កទី៦ ៖ ពង្រឹងតួនាទី ភារកិច្ច និងធ្វើបច្ចុប្បន្នភាព គ.អ.ភ
- ៣.៦.៧.ស.កទី៧ ៖ ផ្សព្វផ្សាយ និងបង្កើនឥណទានជនបទ

## ៤.កម្មវិធីទី៤ ៖ សេវាគាំទ្ររដ្ឋបាល ហិរញ្ញវត្ថុ និងកិច្ចការទូទៅ

នៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ការកសាងសមត្ថភាព និងអភិវឌ្ឍន៍ស្ថាប័នជាអាទិភាពទី១ ដែលរាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ខ្លាំងជាងគេ ។ ការរីកចំរើននៃបច្ចេកវិទ្យាឌីជីតាល់ បានជួយសម្រួលដល់ការងារយ៉ាងច្រើនលើគ្រប់វិស័យទាំងផ្នែកសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ពិសេសទាក់ទងនឹងការបង្កើនល្បឿងអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច ។ ក្រសួងអភិវឌ្ឍន៍ជនបទបានខិតខំបណ្តុះបណ្តាលមន្ត្រីជំនាញបច្ចេកទេស រដ្ឋបាល ផែនការ ហិរញ្ញវត្ថុ សវនកម្ម ដើម្បីរួមចំណែកក្នុងកម្មវិធីកំណែទម្រង់ផ្សេងៗរបស់រាជរដ្ឋាភិបាល ដោយបានទទួលជោគជ័យជាបន្តបន្ទាប់ ។ ក្នុងនីតិកាលទី៦ នៃរដ្ឋសភានេះ ក្រសួងបានរៀបចំកម្មវិធីទី៤ ដើម្បីពង្រឹងសេវាគាំទ្ររដ្ឋបាល ហិរញ្ញវត្ថុ និងកិច្ចការទូទៅ ក្នុងការជំរុញឲ្យមានអភិបាលកិច្ចល្អ ការអនុវត្តកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ

និងកំណែទម្រង់ដទៃទៀតឲ្យទទួលបានជោគជ័យ ។ កម្មវិធីទី៤ មានអនុកម្មវិធីចំនួន ៧ និងចង្កោមសកម្មភាពចំនួន ៥៣ និងសកម្មភាពចំនួន ១០០ ដូចខាងក្រោម៖

## ៤.១.អនុកម្មវិធីទី១៖ពង្រឹងគុណភាពប្រព័ន្ធគ្រប់គ្រងផែនការអភិវឌ្ឍន៍ជនបទ

- ៤.១.១.ច.សទី១ ៖ ពង្រឹងគុណភាពផែនការយុទ្ធសាស្ត្រថវិកា និងថវិកាប្រចាំឆ្នាំ
- ៤.១.២.ច.សទី២ ៖ បច្ចុប្បន្នភាពទិន្នន័យស្ថិតិវិស័យអភិវឌ្ឍន៍ជនបទ
- ៤.១.៣.ច.សទី៣៖គាំទ្រភាពធន់នឹងការប្រែប្រួលអាកាសធាតុក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទ
- ៤.១.៤.ច.សទី៤ ៖ គ្រប់គ្រងផ្សព្វផ្សាយព័ត៌មានវិស័យអភិវឌ្ឍន៍ជនបទ
- ៤.១.៥.ច.សទី៥ ៖ ពង្រឹងកិច្ចសហប្រត្តិការជាអង្គការមិនមែនរដ្ឋាភិបាល
- ៤.១.៦.ច.សទី៦ ៖ តាមដាន និងវាយតម្លៃផែនការប្រចាំឆ្នាំឆ្ពោះទៅរកបាយការណ៍សមិទ្ធកម្ម

## ៤.២.អនុកម្មវិធីទី២៖បង្កើនប្រសិទ្ធភាពការប្រើប្រាស់ថវិកាកម្មវិធី

- ៤.២.១.ច.សទី១ ៖ ការផ្សព្វផ្សាយលទ្ធផលនៃការអនុវត្តថវិកាកម្មវិធី
- ៤.២.២.ច.សទី២ ៖ ប្រសិទ្ធភាពនៃការអនុវត្តថវិកាកម្មវិធី
- ៤.២.៣.ច.សទី៣ ៖ ការពង្រឹងសមត្ថភាពគ្រប់គ្រងបញ្ជីសារពើភណ្ឌ
- ៤.២.៤.ច.សទី៤ ៖ ពង្រឹងការប្រើប្រាស់ប្រព័ន្ធ FMIS

## ៤.៣.អនុកម្មវិធីទី៣៖បង្កើនប្រសិទ្ធភាពសវនកម្មផ្ទៃក្នុង និងអធិការកិច្ច

- ៤.៣.១.ច.សទី១ ៖ សិក្ខាសាលាផ្សព្វផ្សាយសវនកម្មផ្ទៃក្នុង
- ៤.៣.២.ច.សទី២ ៖ ប្រតិបត្តិការសវនកម្មផ្ទៃក្នុង
- ៤.៣.៣.ច.សទី៣ ៖ តាមដានការអនុវត្តតាមអនុសាសន៍សវនកម្មផ្ទៃក្នុង
- ៤.៣.៤.ច.សទី៤ ៖ ចុះអធិការកិច្ចតាមមន្ទីរអភិវឌ្ឍន៍ជនបទរាជធានីខេត្ត
- ៤.៣.៥.ច.សទី៥ ៖ ផ្សព្វផ្សាយនីតិវិធីអធិការកិច្ច

## ៤.៤.អនុកម្មវិធីទី៤៖ ការពង្រឹងស្ថាប័ន និងអភិវឌ្ឍន៍ធនធានមនុស្ស

- ៤.៤.១.ច.សទី១ ៖ ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍ធនជានមនុស្ស
- ៤.៤.២.ច.សទី២ ៖ ការពង្រឹងសមត្ថភាពមន្ត្រីរាជការក្រសួងអភិវឌ្ឍន៍ជនបទ
- ៤.៤.៣.ច.សទី៣ ៖ ការស្រាវជ្រាវ និងផលិតព្រឹត្តិប័ត្រព័ត៌មាន
- ៤.៤.៤.ច.សទី៤៖ ការបណ្តុះបណ្តាលប្រជាពលរដ្ឋជនបទឱ្យមានបំណិនប្រសព្វក្នុងការអភិវឌ្ឍជីវភាពគ្រួសារប្រកបដោយនិរន្តភាព

### ៤.៥.អនុកម្មវិធីទី៥៖ ប្រសិទ្ធភាពការងាររដ្ឋបាល និងយេនឌ័រ

- ៤.៥.១.ច.សទី១ ៖ ការងារយេនឌ័រ
- ៤.៥.២.ច.សទី២ ៖ ការងារអេប់រំ ជំងឺឆ្លង និងសុខភាពផ្លូវភេទ
- ៤.៥.៣.ច.សទី៣ ៖ ការងារជនពិការ
- ៤.៥.៤.ច.សទី៤ ៖ ពង្រឹងសមត្ថភាពរដ្ឋបាល និងបុគ្គលិក

### ៤.៦.អនុកម្មវិធីទី៦៖សេវាគាំទ្រគោលនយោបាយ

- ៤.៦.១.ច.សទី១ ៖ សេវាគាំទ្ររដ្ឋបាល ហិរញ្ញវត្ថុ និងគោលនយោបាយ
- ៤.៦.២.ច.សទី២ ៖ ការផ្សព្វផ្សាយលទ្ធផលសន្និបាតប្រចាំឆ្នាំ
- ៤.៦.៣.ច.សទី៣ ៖ ការជួសជុលថែទាំអាគាររដ្ឋបាល
- ៤.៦.៤.ច.សទី៤ ៖ ការផ្គត់ផ្គង់សម្ភារៈបរិក្ខារបច្ចេកទេសមិនមែនព័ត៌មានវិទ្យា
- ៤.៦.៥.ច.សទី៥ ៖ ការផ្គត់ផ្គង់សម្ភារៈបរិក្ខារបច្ចេកទេសព័ត៌មានវិទ្យា

### ៤.៧.អនុកម្មវិធីទី៧៖ ការពង្រឹងសមត្ថភាព និងសេវាគាំទ្រដោយមន្ទីររាជធានីខេត្តទាំង២៥

- ៤.៦.១.ស.កទី១ ៖ សេវាគាំទ្ររដ្ឋបាល ហិរញ្ញវត្ថុ និងបៀវត្ស
- ៤.៦.២.ស.កទី២ ៖ ពង្រឹងប្រតិបត្តិការផែនការអង្គភាពថវិកា
- ៤.៦.៣.ស.កទី៣ ៖ ពង្រឹងរដ្ឋបាល និងកិច្ចការទូទៅ
- ៤.៦.៤.ស.កទី៤ ៖ ពង្រឹងការគ្រប់គ្រងទ្រព្យរដ្ឋ និងការស្រង់ទិន្នន័យបញ្ជីសារពើភណ្ឌជនបទ

## IV. រចនាសម្ព័ន្ធថវិកាកម្មវិធីក្រសួងអភិវឌ្ឍន៍ជនបទ

រចនាសម្ព័ន្ធគ្រប់គ្រងថវិកាកម្មវិធីរបស់ក្រសួងអភិវឌ្ឍន៍ជនបទមាន ៣ ថ្នាក់ ៖

**ថ្នាក់ទី១៖** ជាកម្រិតកម្មវិធី ដែលគ្រប់គ្រងដោយអគ្គនាយក/អនុរដ្ឋលេខាធិការមួយរូបលើកម្មវិធីនីមួយៗ ដែលត្រូវទទួលខុសត្រូវការអនុវត្តក្នុងកម្រិតគោលនយោបាយរបស់ក្រសួងនិងរាជរដ្ឋាភិបាល ។

**ថ្នាក់ទី២៖** ជាកម្រិតអនុកម្មវិធី ដែលគ្រប់គ្រងដោយនាយកដ្ឋានជំនាញ ដឹកនាំដោយប្រធាននាយកដ្ឋាន និងទទួលខុសត្រូវក្នុងការអនុវត្តកម្រិតយុទ្ធសាស្ត្រ ទទួលខុសត្រូវគ្រប់គ្រង និងអនុវត្តនូវជំនាញរបស់ខ្លួនទៅតាមតួនាទី និងភារកិច្ចរបស់នាយកដ្ឋាន ។

**ថ្នាក់ទី៣៖**ជាកម្រិតចង្កោមសកម្មភាព និងសកម្មភាពដែលគ្រប់គ្រងដោយថ្នាក់ការិយាល័យជំនាញ និងមន្ទីរជំនាញរាជធានី-ខេត្តទាំង ២៥ ដែលជាអ្នកអនុវត្តផែនការសកម្មភាពដោយផ្ទាល់ ហើយត្រូវទទួលខុសត្រូវចំពោះផែនការសកម្មភាព និងសូចនាករដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទ ។



# តារាងឧបសម្ព័ន្ធផែនការយុទ្ធសាស្ត្រថវិកា
# ឆ្នាំ ២០២០-២០២២ របស់ក្រសួងអភិវឌ្ឍន៍ជនបទ

តារាងទី១.

# តារាងសង្ខេបកម្មវិធីវិនិយោគសាធារណៈ (PIP) ឆ្នាំ ២០២០-២០២២

## ១.គម្រោងស្នើសុំថ្មី

| លរ. | ឈ្មោះគម្រោង | នាយកដ្ឋានអនុវត្តន៍ | តម្លៃ ($) | រយៈពេល |
|---|---|---|---|---|
| ១ | ការកែលម្អផ្លូវពីក្រាលក្រួសក្រហម ទៅជាកៅស៊ូពីរជាន់និងកម្រាលផ្សេងទៀត | ផ្លូវលំជនបទ | 40,251,000 | 2020-2022 |
| ២ | ការស្តារ ការជួសជុល និងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធជនបទ/ | ផ្លូវលំជនបទ | 95,100,000 | 2020-2022 |
| ៣ | កសាងមជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍន៍ជនជាតិដើមភាគតិច | អភិវឌ្ឍន៍ជនជាតិភាគតិច | 1,929,000 | 2020-2022 |
| ៤ | អភិវឌ្ឍន៍ចម្រុះសហគមន៍ជនជាតិដើមភាគតិច | អភិវឌ្ឍន៍ជនជាតិភាគតិច | 170,000 | 2020-2022 |
| ៥ | ប្រព័ន្ធគ្រប់គ្រងទិន្នន័យសម្រាប់វិស័យទឹកស្អាត និងអនាម័យ | ថែទាំសុខភាពជនបទ | 6,600,000 | 2020-2022 |
| ៦ | លើកកម្ពស់ការផ្តល់សេវាអនាម័យជនបទ | ថែទាំសុខភាពជនបទ | 6,450,000 | 2020-2022 |
| ៧ | បង្កើនសន្តិសុខស្បៀងជាលក្ខណៈគ្រួសារ | អភិវឌ្ឍន៍សហគមន៍ជនបទ | 1,755,000 | 2020-2022 |
| ៨ | គម្រោងអភិវឌ្ឍន៍ជនបទដោយប្រើប្រាស់វិធីសាស្ត្រ "ចលនាភូមិថ្មី " | អភិវឌ្ឍន៍សហគមន៍ជនបទ | 8,000,000 | 2020-2022 |
| ៩ | បញ្ជ្រាការត្រៀមបង្ការ និងកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយក្នុងសហគមន៍ | អភិវឌ្ឍន៍សហគមន៍ជនបទ | 300,000 | 2020-2022 |
| ១០ | ពង្រឹងសកម្មភាពមជ្ឈមណ្ឌលអភិវឌ្ឍន៍សហគមន៍ | អភិវឌ្ឍន៍សហគមន៍ជនបទ | 1,410,000 | 2020-2022 |
| ១១ | ពង្រឹងសមត្ថភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (ភ.អ.គ ) | អភិវឌ្ឍន៍សហគមន៍ជនបទ | 810,000 | 2020-2022 |
| ១២ | ការពង្រឹងការគ្រប់គ្រងការងាររដ្ឋបាល និងបុគ្គលិក រដ្ឋបាល និងបុគ្គលិក | រដ្ឋបាល និងបុគ្គលិក | 165,000 | 2020-2022 |
| ១៣ | គម្រោងកែលម្អ និងស្តារប្រព័ន្ធប្រឡាយស្រោចស្រពខ្នាតតូច | ផ្គត់ផ្គង់ទឹកជនបទ | 20,000,000 | 2020-2022 |
| ១៤ | គម្រោងផ្គត់ផ្គង់ទឹកស្អាតជនបទទូទាំង២៥រាជធានី ខេត្ត | ផ្គត់ផ្គង់ទឹកជនបទ | 63,700,000 | 2020-2022 |
| ១៥ | គម្រោងផ្គត់ផ្គង់ទឹកជនបទក្នុងប្រទេសកម្ពុជា | ផ្គត់ផ្គង់ទឹកជនបទ | 65,000,000 | 2020-2022 |
| ១៦ | គាំទ្រកិច្ចសវនកម្មផ្ទៃក្នុង | សវនកម្មផ្ទៃក្នុង | 180,000 | 2020-2022 |
| ១៧ | មជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញមូលដ្ឋាន | បណ្តុះបណ្តាល និងស្រាវជ្រាវ | 900,000 | 2020-2022 |

| | | | | |
|---|---|---|---|---|
| ១៨ | ជំនាញវាយតម្លៃ និងស្រាវជ្រាវ (ការអប់រំផ្សព្វផ្សាយ និងស្រាវជ្រាវ ) | បណ្តុះបណ្តាល និងស្រាវជ្រាវ | 514,000 | 2020-2022 |
| ១៩ | ការអភិវឌ្ឍធនធានមនុស្ស | បណ្តុះបណ្តាល និងស្រាវជ្រាវ | 2,100,000 | 2020-2022 |
| ២០ | ផ្តល់មុខជំនាញជាមូលដ្ឋាន និងសហគ្រិនភាព | បណ្តុះបណ្តាល និងស្រាវជ្រាវ | 300,000 | 2020-2022 |
| ២១ | គម្រោងឥណទានសហគមន៍សម្រាប់អភិវឌ្ឍន៍ជនបទ | អភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ | 2,000,000 | 2020-2022 |
| ២២ | ការបង្កើនប្រាក់ចំណូលតាមរយៈកម្មវិធីអភិវឌ្ឍន៍សហគ្រិនភាពជនបទ | អភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ | 3,000,000 | 2020-2022 |
| ២៣ | ការលើកកម្ពស់សេដ្ឋកិច្ចជនបទតាមរយៈការជំរុញទីផ្សារផលិតផលជនបទ | អភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ | 4,000,000 | 2020-2022 |
| ២៤ | ការអភិវឌ្ឍន៍សហគ្រាសនិងជំនាញខ្នាតតូច | អភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ | 1,892,300 | 2020-2022 |
| ២៥ | ឥណទានជនបទ | អភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ | 2,360,000 | 2020-2022 |
| | **សរុប** (I) | | **328,886,300** | |

## ២. គម្រោងកំពុងដំណើរការ

| លរ. | ឈ្មោះគម្រោង | តម្លៃ ($) | ឆ្នាំចាប់ផ្តើម | ឆ្នាំបញ្ចប់ |
|---|---|---|---|---|
| ១ | ការអភិវឌ្ឍន៍ភូមិចម្រុះ | 4,000,000 | 01/01/20 | 31/12/22 |
| ២ | គម្រោងផ្គត់ផ្គង់ទឹកស្អាតជនបទ និងអនាម័យដំហានទី៣ ( ហិរញ្ញប្បទានបន្ថែម) | 47,000,000 | 01/01/19 | 31/12/22 |
| ៣ | គម្រោងផ្គត់ផ្គង់ទឹកជនបទ | 2,510,000 | 10/03/17 | 31/12/20 |
| ៤ | គម្រោងសាច់ប្រាក់ពលកម្មដើម្បីអភិវឌ្ឍហេដ្ឋរចនាសម្ព័ន្ធជនបទនិងការគាំទ្រកសិករ | 27,361,776 | 01/04/17 | 31/03/20 |
| ៥ | កម្មវិធីកែលម្អហេដ្ឋារចនាសម្ព័ន្ធជនបទដំហានទី៦ | 6,171,000 | 6/1/2018 | 30/06/2020 |
| ៦ | គម្រោងកែលម្អផ្លូវជនបទដំហាន ២ | 192,710,000 | 01/01/2015 | 31/12/2020 |
| ៧ | គម្រោងកែលម្អផ្លូវជនបទដំហាន ៣ | 133,574,000 | 01/01/2019 | 31/12/2025 |
| ៨ | ផ្តល់មុខជំនាញជាមូលដ្ឋានលើការផលិតចង្ក្រានជីវឧស្ម័ននិងកែលម្អ | 2,150,000 | 15/01/2020 | 26/12/22 |
| | **សរុប** (II) | **415,476,776** | | |
| | **សរុបរួម** (I)+(II) | **744,363,076** | | |

# កម្មវិធី អនុកម្មវិធី អ្នកគ្រប់គ្រង និងអង្គភាពទទួលខុសត្រូវថ្នាក់កណ្តាល

**តារាង ២**

| គោលបំណងគោលនយោបាយ | ឈ្មោះ កម្មវិធី និង អនុកម្មវិធី | អ្នកគ្រប់គ្រង | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|
| លើកកម្ពស់គុណភាព និងគុណតម្លៃនៃជីវិតរស់នៅរបស់ប្រជាជនជនបទប្រកបដោយបរិយាប័ន្ន ទាំងផ្នែកសេដ្ឋកិច្ច សង្គម និងវប្បធម៌។ | **កម្មវិធីទី១ ៖អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងគមនាគមន៍** | ឯ.ឧ.ភួង សោភា | អនុរដ្ឋលេខាធិការ |
| | អនុកម្មវិធីទី១.១ ៖ ការជួសជុល និងរក្សាគុណភាពផ្លូវជនបទ | លោក គង់ កឿន | នាយកដ្ឋានផ្លូវលំជនបទ |
| | អនុកម្មវិធីទី១.២ ៖ ការពង្រីកវិសាលភាពនៃការស្ថាបនា លើកកម្រិតហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ | លោក គង់ កឿន | នាយកដ្ឋានផ្លូវលំជនបទ |
| | អនុកម្មវិធីទី១.៣ ៖ ការរៀបចំបញ្ជីសារពើភណ្ឌ និងមូលដ្ឋានទិន្នន័យផ្លូវជនបទ | លោក គង់ កឿន | នាយកដ្ឋានផ្លូវលំជនបទ |
| | អនុកម្មវិធីទី១.៤ ៖ ការផ្តល់សេវាហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តជនបទដោយមន្ទីរជំនាញ ២៥ | ប្រធានមន្ទីរ | មន្ទីររាជធានី ខេត្តចំនួន ២៥ |
| | **កម្មវិធីទី២ ៖ កែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ** | | |
| | អនុកម្មវិធីទី២.១ ៖ ការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធទឹកស្អាតជនបទ | លោក ស្រ៊ិន ពុទ្ធី | នាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ |
| | អនុកម្មវិធីទី២.២ ៖ ការបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ទឹកស្អាតជនបទ | លោក ស្រ៊ិន ពុទ្ធី | នាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ |
| | អនុកម្មវិធីទី២.៣ ៖ ការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តអនាម័យជនបទ | លោក លុនសាយ តេង | នា.សុខភាពជនបទ |
| | អនុកម្មវិធីទី២.៤ ៖ ការលើកកម្ពស់ការរស់នៅស្អាត ការអប់រំសុខភាព និងអនាម័យជនបទ | លោក លុនសាយ តេង | នា.សុខភាពជនបទ |
| | អនុកម្មវិធីទី២.៥ ៖ ការផ្តល់សេវាសុខភាព និងលក្ខខ័ណ្ឌនៃការរស់នៅសម្រាប់សាធារណៈជនដោយមន្ទីរជំនាញ ២៥ | ប្រធានមន្ទីរ | មន្ទីររាជធានី ខេត្តចំនួន ២៥ |

| | | | |
|---|---|---|---|
| | **កម្មវិធីទី៣ ៖ ពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ** | | |
| | អនុកម្មវិធីទី៣.១ ៖ ការជំរុញបង្កើតការងារ និងមុខរបរនៅជនបទ | លោក គី សុផល | នា.អភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ |
| | អនុកម្មវិធីទី៣.២ ៖ ការជំរុញសកម្មភាពសេដ្ឋកិច្ចគ្រួសារនៅជនបទ | លោក គី សុផល | នា.អភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ |
| | អនុកម្មវិធីទី៣.៣ ៖ ការបណ្តុះបណ្តាលធនធានមនុស្ស និងជំនាញអាជីព | លោក តូច ស៊ីផាត | នា.បណ្តុះបណ្តាល និងស្រាវជ្រាវ |
| | អនុកម្មវិធីទី៣.៤ ៖ ជំរុញការអភិវឌ្ឍចម្រុះសម្រាប់សហគមន៍ជនបទ | លោក អឿន ជារិទ្ធ | នា.អភិវឌ្ឍន៍សហគមន៍ |
| | អនុកម្មវិធីទី៣.៥ ៖ ការអភិវឌ្ឍ និងអភិរក្សជនជាតិដើមភាគតិច | លោក ស៊ុត សឿង | នា.អភិវឌ្ឍន៍ជនជាតិដើមភាគតិច |
| | អនុកម្មវិធីទី៣.៦ ៖ ការលើកកម្ពស់កម្រិតជីវភាពរស់នៅតាមជនបទ ដោយមន្ទីរជំនាញទាំង២៥ | ប្រធានមន្ទីរ | មន្ទីររាជធានី ខេត្តចំនួន ២៥ |
| | **កម្មវិធីទី៤ ៖ សេវាគាំទ្ររដ្ឋបាល ហិរញ្ញវត្ថុ និងកិច្ចការទូទៅ** | ឯ.ឧ លាង សេង | អគ្គនាយករដ្ឋបាល ហិរញ្ញវត្ថុ |
| | អនុកម្មវិធីទី៤.១ ៖ ការពង្រឹងគុណភាពប្រព័ន្ធគ្រប់គ្រងផែនការអភិវឌ្ឍន៍ជនបទ | ឯ.ឧ ម៉ា សុវណ្ណា | នា.ផែនការ និងទំ.ទំ.សាធារណៈ |
| | អនុកម្មវិធីទី៤.២ ៖ការបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ថវិកាកម្មវិធី | លោក ប៉ាន សុម៉ារ៉ា | នា.ផ្គត់ផ្គង់ និងហិរញ្ញវត្ថុ |
| | អនុកម្មវិធីទី៤.៣ ៖ ការបង្កើនប្រសិទ្ធភាពសវនកម្មផ្ទៃក្នុង និងអធិការកិច្ច | លោក ពេជ្រ សេដ្ឋា | នា.សវនកម្មផ្ទៃក្នុង និងអគ្គាធិការ |
| | អនុកម្មវិធីទី៤.៤ ៖ ការពង្រឹងប្រសិទ្ធភាពគ្រប់គ្រងរដ្ឋបាល និងយេនឌ័រ | លោក លាភ សំណាង | នា.រដ្ឋបាល និងបុគ្គលិក |
| | អនុកម្មវិធីទី៤.៥ ៖ សេវាគាំទ្រគោលនយោបាយ | លោក បាន សុម៉ារ៉ា | នា.ផ្គត់ផ្គង់ និងហិរញ្ញវត្ថុ |
| | អនុកម្មវិធីទី៤.៦ ៖ ការពង្រឹងសមត្ថភាព និងសេវាគាំទ្រដោយមន្ទីររាជធានីខេត្តទាំង២៥ | ប្រធានមន្ទីរ | មន្ទីររាជធានី ខេត្តចំនួន ២៥ |

តារាងទី៣

| គោលបំណងគោលនយោបាយ | អនុកម្មវិធី/ចង្កោមសកម្មភាព/សកម្មភាព | អ្នកគ្រប់គ្រង | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|
| លើកកម្ពស់គុណភាព និងគុណតម្លៃនៃជីវិតរស់នៅរបស់ប្រជាជនជនបទប្រកបដោយបរិយាប័ន្នទាំងផ្នែកសេដ្ឋកិច្ច សង្គម និងវប្បធម៌។ | អនុកម្មវិធីទី១.៤ ៖ ការផ្តល់សេវាហេដ្ឋារចនាសម្ព័ន្ធរូបវន្តជនបទដោយមន្ទីរជំនាញ ២៥ | ប្រធានមន្ទីរ | មន្ទីរអភិវឌ្ឍន៍ជនបទ |
| | ១.៤.១.ស.កទី១ ៖ ការងារថែទាំផ្លូវជនបទជាលក្ខណៈប្រចាំ | ប្រធានការិ.ផ្លូវលំជនបទ | |
| | ១.៤.២.ស.កទី២ ៖ ការងារថែទាំ ជួសជុលស្ពាន និងហេដ្ឋារចនាសម្ព័ន្ធជនបទ | ប្រធានការិ.ផ្លូវលំជនបទ | |
| | ១.៤.៣.ស.កទី៣ ៖ ការងារថែទាំផ្លូវទប់ទល់នឹងការប្រែប្រួលអាកាសធាតុ( ដាំកូនឈើ ) | ប្រធានការិ.ផ្លូវលំជនបទ | |
| | ១.៤.៤.ស.កទី៤ ៖ ការរាប់ចំនួនចរាចរណ៍យានយន្ត | ប្រធានការិ.ផ្លូវលំជនបទ | |
| | ១.៤.៥.ស.កទី៥ ៖ ការសាងសង់ទីទួលសុវត្ថិភាព | ប្រធានការិ.ផ្លូវលំជនបទ | |
| | ១.៤.៦.ស.កទី៦ ៖ ត្រួតពិនិត្យការដឹកជញ្ជូនលើសទំងន់លើផ្លូវជនបទ | ប្រធានការិ.ផ្លូវលំជនបទ | |
| | ២.៥. ការផ្តល់សេវាសុខភាព និងលក្ខខ័ណ្ឌនៃការរស់នៅសម្រាប់សាធារណៈជនដោយមន្ទីរជំនាញ ២៥ | ប្រធានមន្ទីរមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត | |
| | ២.៥.១.ស.កទី១ ៖ ការផ្សព្វផ្សាយ និងអប់រំសហគមន៍ពីលក្ខខណ្ឌនៃការរស់នៅស្អាត | ការិ.ផ្គត់ផ្គង់ទឹកជនបទ | |

| | |
|---|---|
| ២.៥.២.ស.កទី២ ៖ បង្កើនសហគមន៍បញ្ឈប់បន្ទោរបង់ពាសវាលពាសកាល (ODF) | ការិ.សុខភាពជនបទ |
| ២.៥.៣.ស.កទី៣ ៖ ប្រារព្ធទិវាលាងសម្អាតដៃពិភពលោកតាមខេត្ត | ការ.សុខភាពជនបទ |
| ២.៥.៤.ស.កទី៤ ៖ ប្រារព្ធទិវាអនាម័យ ១៣ វិច្ឆិកាតាមខេត្ត | ការិ.សុខភាពជនបទ |
| ២.៥.៥.ស.កទី៥ ៖ ផ្សព្វផ្សាយការប្រើប្រាស់ បរិភោគទឹកស្អាតដោយសុវត្ថិភាព | ការិ.ផ្គត់ផ្គង់ទឹកជនបទ |
| ២.៥.៦.ស.កទី៦ ៖ ការសាងសង់បង្គន់អនាម័យ / បដិភាគសម្ភារៈអនាម័យ | ការិ.ផ្គត់ផ្គង់ទឹកជនបទ |
| ២.៥.៧.ស.កទី៧ ៖ ការងារថែទាំ និងជួសជុលអណ្តូងទឹក | ការិ.ផ្គត់ផ្គង់ទឹកជនបទ |
| ២.៥.៨.ស.កទី៨ ៖ ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធទឹកស្អាតចម្រុះ | ការិ.ផ្គត់ផ្គង់ទឹកជនបទ |
| **៣.៦.អនុកម្មវិធីទី៦ ៖ ការលើកកម្ពស់កម្រិតជីវភាពរស់នៅតាមជនបទដោយមន្ទីរជំនាញទាំង ២៥ រាជធានី ខេត្ត** | **ប្រធានមន្ទីរមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត** |
| ៣.៦.១.ស.កទី១ ៖ ស្រាវជ្រាវតម្រូវការទីផ្សារក្នុងសហគមន៍មូលដ្ឋាន | ការិ.អភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ |
| ៣.៦.២.ស.កទី២ ៖ បណ្តុះបណ្តាលជំនាញមូលដ្ឋានអាជីព | ការិ.បណ្តុះបណ្តាល និងស្រាវជ្រាវ |
| ៣.៦.៣.ស.កទី៣ ៖ បំផុលចលនាមហាជនចូលរួមបង្កើតជំនាញអាជីពផ្ទាល់ខ្លួន | ការិ.បណ្តុះបណ្តាល និងស្រាវជ្រាវ |
| ៣.៦.៤.ស.កទី៤ ៖ ស្រាវជ្រាវ និងបង្កើតគំនិតច្នៃប្រឌិតអភិវឌ្ឍន៍សហគមន៍មូលដ្ឋាន | ការិ.បណ្តុះបណ្តាល និងស្រាវជ្រាវ |

| | |
|---|---|
| ៣.៦.៥.ស.កទី៥ ៖ ផ្សព្វផ្សាយទិវាជនជាតិដើមភាគតិចប្រចាំឆ្នាំ | ការិ.អភិវឌ្ឍន៍ជនជាតិដើមភាគតិច |
| ៣.៦.៦.ស.កទី៦ ៖ ពង្រឹងតួនាទី ភារកិច្ច និងធ្វើបច្ចុប្បន្នភាព គ.អ.ភ | ការិ.អភិវឌ្ឍន៍សហគមន៍ |
| ៣.៦.៧.ស.កទី៧ ៖ ផ្សព្វផ្សាយ និងបង្កើនឥណទានជនបទ | ការិ.អភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ |
| ៣.៦.១.ស.កទី១ ៖ ស្រាវជ្រាវតម្រូវការទីផ្សារក្នុងសហគមន៍មូលដ្ឋាន | ការិ.អភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ |
| **៤.៧.អនុកម្មវិធីទី៧៖ ការពង្រឹងសមត្ថភាព និងសេវាគាំទ្រដោយមន្ទីររាជធានីខេត្តទាំង២៥** | **ប្រធានមន្ទីរមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត** |
| ៤.៦.១.ច.សទី១ ៖ សេវាគាំទ្ររដ្ឋបាល ហិរញ្ញវត្ថុ និងគោលនយោបាយ | ការិ.គណនេយ្យ ហិរញ្ញវត្ថុ ការិរដ្ឋបាល |
| ៤.៦.២.ស.កទី២ ៖ ពង្រឹងប្រតិបត្តិការផែនការអង្គភាពថវិកា | ការិ.ផែនការ ស្ថិតិ |
| ៤.៦.៣.ស.កទី៣ ៖ ពង្រឹងរដ្ឋបាល និងកិច្ចការទូទៅ | ការិ.រដ្ឋបាល |
| ៤.៦.៤.ស.កទី៤ ៖ ពង្រឹងការគ្រប់គ្រងទ្រព្យរដ្ឋនិងការស្រង់ទិន្នន័យបញ្ជីសារពើភណ្ឌជនបទ | ការិ.គណនេយ្យនិងហិរញ្ញវត្ថុ ការិ.ផ្លូវជនបទ |

# ការកំណត់សូចនាករនិងគោលដៅសូចនាករនៃកម្មវិធី និងអនុកម្មវិធី

តារាងទី៤

| តារាង ២ ÷ ការកំណត់សូចនាករ និងគោលដៅសូចនាករ នៃកម្មវិធី និងអនុកម្មវិធី | | | | | | |
|---|---|---|---|---|---|---|
| ឈ្មោះគោលបំណង គោលនយោបាយ កម្មវិធីនិងអនុកម្មវិធី | សូចនាករលទ្ធផលក្នុងឆ្នាំនិងគោលដៅ | | | | សូចនាករលទ្ធផលចុងក្រោយនិងគោលដៅ | |
| | សូចនាករ | ឆ្នាំ២០១៨ ( អនុវត្ត) | ឆ្នាំ២០១៩ (បច្ចុប្បន្ន) | ឆ្នាំ២០២០ (គ្រោង) | សូចនាករ | គោលដៅ |
| គោលបំណងគ.ប ៖ លើកកម្ពស់គុណភាព និងគុណតម្លៃនៃជីវិតរស់នៅរបស់ប្រជាជនជនបទប្រកបដោយបរិយាប័ន្ន ទាំងផ្នែកសេដ្ឋកិច្ច សង្គម និងវប្បធម៌ ។ | | | | | | |
